# លិខិតទូន្មានមេដឹកនាំព្រះសហគមន៍

តាំងពីសតវត្សទី១៩ មក អ្នកវិភាគធ្លាប់ហៅ លិខិតទី១ និងទី២ របស់គ្រីស្តទូតប៉ូល ផ្ញើជូនលោកធីម៉ូថេ និង លិខិតផ្ញើជូនលោកទីតូ ថា « លិខិតទូន្មានមេដឹកនាំព្រះសហគមន៍» ព្រោះក្នុងលិខិតទាំងបីនេះ គ្រីស្តទូតប៉ូលទូន្មានលោកធីម៉ូថេនិងលោកទីតូ ក្នុងការចាត់ចែង និងណែនាំព្រះសហគមន៍។

## លោកធីម៉ូថេ

គ្រីស្តទូតប៉ូលជួបលោកធីម៉ូថេ នៅក្រុងលីស្ត្រា ពេលលោកធ្វើដំណើរប្រកាសដំណឹងល្អ លើកទីពីរ (កក ១៦,១-៣)។ គាត់ជាកូនរបស់ស្ត្រីជាតិយូដាម្នាក់ ដែលជាគ្រីស្តបរិស័ទ ឪពុកគាត់ជាជនជាតិក្រិក មិនមែនជាគ្រីស្តបរិស័ទទេ។ គ្រីស្តទូតប៉ូលធ្វើពិធីកាត់ស្បែកឲ្យគាត់ តាំងពីពេលនោះមក លោកធីម៉ូថេរួមធ្វើដំណើរជាមួយលោកប៉ូល ក្នុងឋានៈជាសហការីដ៏ជិតស្និទ្ធក្នុងការប្រកាសដំណឹងល្អ។ គាត់ក៏រួមជាមួយលោកប៉ូល នៅពេលលោកសរសេរលិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងថេស្សាឡូនិក ក្រុងភីលីព ក្រុងកូរិនថូទី២ និងលោកភីលេម៉ូនដែរ។

## លោកទីតូ

លោកទីតូ ជាជនជាតិក្រិកម្នាក់ (កាឡ ២,៣) ហើយក៏ជាសហការីរបស់លោកប៉ូលដែរ។ គាត់ជួយសម្រុះសម្រួលគ្រីស្តបរិស័ទក្រុងកូរិនថូ ដែលទាស់ទែងគ្នា ឲ្យចុះសម្រុងគ្នា (២ ករ ៧,៧-១៥)។ តាមលិខិតនេះ គាត់ស្ថិតនៅកោះក្រែត ព្រោះគ្រីស្តទូតប៉ូលប្រគល់ភារកិច្ចឲ្យគាត់ចាត់ចែងព្រះសហគមន៍នៅកោះនោះ (ទត១,៥)។ តាម ២ ធម ៤,១០ ពេលគ្រីស្តទូតប៉ូលជាប់ឃុំឃាំង គាត់នៅស្រុកដាលម៉ាទី។

## លិខិតទាំងបី

លិខិតទាំងបីនេះប្លែកពីលិខិតទាំង៩ ឯទៀតៗនោះ គឺលោកសរសេរជូនបុគ្គលម្នាក់ មិនមែនផ្ញើជូនព្រះសហគមន៍មួយទេ លោកប្រើពាក្យប្លែកពីគោលការណ៍នៃជំនឿក៏ប្លែកដែរ។ ល។ ហេតុនេះហើយ បានជាអ្នកវិភាគមិនដឹងច្បាស់ថា នរណាសរសេរលិខិតទាំងបីនោះ។

- អ្នកខ្លះសន្និដ្ឋានថា គ្រីស្តទូតប៉ូលសរសេរលិខិតទាំងបីនេះ នៅពេលលោកជាប់ឃុំឃាំងនៅក្រុងរ៉ូម។ ប៉ុន្តែ តាម កក ២៨,២៨-៣១ គ្រីស្តទូតប៉ូលរស់នៅក្នុងទីក្រុងរ៉ូម ដោយមានសេរីភាព។ អ្នកវិភាគទាំងនោះសន្និដ្ឋានថា ក្រោយពីបានសេរីភាពពេញទីហើយ គ្រីស្តទូតប៉ូលត្រឡប់ទៅមជ្ឈិមបូព៌ា រួចលោកជាប់ឃុំឃាំងនៅក្រុងរ៉ូមម្តងទៀតយ៉ាងសែនពិបាក ដូចមានចែងក្នុងលិខិតទាំងនេះ។ លោកយល់ឃើញថា បន្តិចទៀត លោកត្រូវគេធ្វើឃាត (២ ធម ៤,៦-១៨)។

- អ្នកខ្លះទៀតសន្និដ្ឋានថា មិនមែនគ្រីស្តទូតប៉ូលសរសេរទេ ព្រោះពិបាកស្មានអំពីសកម្មភាពរបស់លោក ក្រោយពីបានសេរីភាពនៅក្រុងរ៉ូម។ ម្យ៉ាងទៀតក្នុងលិខិតទាំងបីនេះ មានចែងអំពីសភាពការណ៍ព្រះសហគមន៍នៅចុងសតវត្សទី១។ ហេតុនេះហើយ បានជាអ្នកវិភាគទាំងនោះសន្និដ្ឋានថា កូនចៅលោកប៉ូលនិពន្ធប្រហែលនៅ គ.ស. ៨០-៩០ (ព្រោះសភាពការណ៍ព្រះសហគមន៍ ប្រហែលនឹងសភាពការណ៍ក្នុងគម្ពីរកិច្ចការ ហើយក៏គ្មានចែងអំពីរដ្ឋអំណាចបៀតបៀនគ្រីស្តបរិស័ទ ដូចរដ្ឋបៀតបៀនគេតាំងពីឆ្នាំ ៩០ តទៅ។ អ្នកនិពន្ធទូន្មានព្រះសហគមន៍នៅមជ្ឈិមបូព៌ា ដោយយកឈ្មោះគ្រីស្តទូតប៉ូលមកសំអាង តាមទម្លាប់នៅសម័យនោះ។ ទោះជាយ៉ាងណាក៏ដោយ គឺព្រះសហគមន៍ទទួលលិខិតទាំងនោះក្នុងសាសនបញ្ញត្តិ តាំងពីដើមរៀងមក។ លិខិតផ្ញើជូនលោកទីតូចែងមុនគេ បន្ទាប់មក លិខិតទី១ ផ្ញើជូនលោកធីម៉ូថេ បន្ទាប់មកទៀត លិខិតទី២ ផ្ញើជូនលោកធីម៉ូថេ។

# ក្រុងកូឡូស ផ្ញើជូនលោក ភីលេម៉ូន
# និង ផ្ញើជូនគ្រីស្តបរិស័ទក្រុងអេភេសូ

## ពាក្យលំនាំ

លិខិតទាំងបីជាប់ជាមួយគ្នា។ អ្នកវិភាគតែងរាប់បញ្ចូល «លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងភីលីពក្រុងអេភេសូ ក្រុងកូឡូស និងផ្ញើជូនលោកភីលេម៉ូន » ក្នុងបញ្ជី« លិខិតគ្រីស្តទូតប៉ូលសរសេរនៅពេលលោកជាប់ឃុំឃាំង» ប៉ុន្តែ លិខិតទាំងបួននោះប្លែកៗពីគ្នា គឺ «លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងភីលីព» ប្រហែលនឹង «លិខិតផ្ញើជូន ទៅគ្រីស្តបរិស័ទក្រុងថេស្សាឡូនិក» រីឯលិខិតផ្ញើជូនទៅគ្រីស្តបរិស័ទក្រុងអេភេសូ និងក្រុងកូឡូសស្រដៀងគ្នា។ ហេតុនេះហើយ បានជាអ្នកវិភាគតែងសន្និដ្ឋានថា គ្រីស្តទូតប៉ូលសរសេរលិខិត ផ្ញើជូនទៅគ្រីស្តបរិស័ទក្រុងភីលីព នៅពេលលោកជាប់ឃុំឃាំងនៅក្រុងអេភេសូប្រហែលនៅគ.ស.៥៦-៥៧។

រីឯលិខិតផ្ញើជូនទៅគ្រីស្តបរិស័ទ ក្រុងអេភេសូនិងក្រុងកូឡូស អ្នកវិភាគខ្លះសន្និដ្ឋានថាលោកសរសេរ នៅពេលលោកជាប់ឃុំឃាំងនៅក្រុងសេសារេ (តាម កក ២៣,២៣-២៦,៣២ គឺនៅ គ.ស.៥៨-៦០) ឬនៅពេលលោកជាប់ឃុំឃាំងនៅក្រុងរ៉ូម (គ.ស.៦១-៦៣)។ ប៉ុន្តែសព្វថ្ងៃ អ្នកវិភាគជាច្រើនសន្និដ្ឋានថា កូនចៅគ្រីស្តទូតប៉ូលបានសរសេរ យូរឆ្នាំក្រោយដើម្បីដោះស្រាយបញ្ហាថ្មី ក្នុងព្រះសហគមន៍ទាំងនោះ ដោយយកឈ្មោះគ្រីស្តទូតប៉ូលមកអះអាង តាមទម្លាប់នៅសម័យនោះ។ ទោះជាយ៉ាងណាក៏ដោយក៏ព្រះសហគមន៍ទទួលលិខិតទាំងនេះក្នុងសាសនបញ្ញត្តិរបស់ខ្លួន គឺទុកជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

# លិខិតរបស់គ្រីស្តទូតប៉ូល

# ផ្ញើជូនលោកភីលេម៉ូន

## ពាក្យលំនាំ

**លោកភីលេម៉ូន** ៖ លោកភីលេម៉ូន ជាអ្នកដ៏សំខាន់ក្នុងព្រះសហគមន៍ក្រុងកូឡូស។ គ្រីស្តបរិស័ទធ្លាប់ប្រជុំគ្នានៅផ្ទះគាត់។ គាត់ត្រូវជាមិត្តភក្តិរបស់គ្រីស្តទូតប៉ូល (១)។

## លិខិតគ្រីស្តទូតប៉ូល

ទាសកររម្នាក់របស់លោកភីលេម៉ូន ឈ្មោះអូនេស៊ីម រត់ចេញពីផ្ទះ ហើយត្រូវទទួលទោសជាទម្ងន់តាមច្បាប់។ អូនេស៊ីម ទៅជួបគ្រីស្តទូតប៉ូល ហើយក៏ប្រែចិត្តជឿលើព្រះយេស៊ូដែរ។ គ្រីស្តទូតប៉ូលសម្រេចចិត្ត ចាត់គាត់ឲ្យវិលត្រឡប់ទៅរកម្ចាស់របស់ខ្លួនវិញ។ លោកសរសេរលិខិតឲ្យគាត់កាន់ទៅជាមួយផង។ ក្នុងលិខិតនេះ លោកប៉ូលសុំឲ្យលោកភីលេម៉ូន ទទួលអូនេស៊ីម ក្នុងឋានៈជាបងប្អូនរួមជំនឿ គឺមិនមែនទុកជាទាសករទៀតទេ។

គ្រីស្តទូតប៉ូលជាប់ឃុំឃាំង(៩)។ អ្នកវិភាគជាច្រើនសន្និដ្ឋានថា លោកសរសេរនេះនៅក្រុងអេភេសូ នា គ.ស.៥៦-៥៧។ អ្នកខ្លះទៀតសន្និដ្ឋានថា គ្រីស្តទូតប៉ូលសរសេរនៅពេលលោកសរសេរលិខិតផ្ញើជូនគ្រីស្តបរិស័ទ ក្រុងកូឡូស ព្រោះមានឈ្មោះសហការីធ្វើការជាមួយលោកដូចគ្នា (កឡ ៤,៧-១៤; ភម ២៣-២៤) គឺពេលលោកជាប់ឃុំឃាំង នៅក្រុងសេសារេ (គ.ស. ៥៨-៦០) ឬនៅក្រុងរ៉ូម (៦១-៦៣)។

## សារៈសំខាន់

ក្នុងចំណោមលិខិតគ្រីស្ដទូតប៉ូល លិខិតនេះខ្លីជាងគេ តែមានសារៈសំខាន់ ព្រោះលិខិតនេះ នាំឲ្យស្គាល់ទំនាក់ទំនងថ្មីរវាងគ្រីស្ដទូតប៉ូលនឹងគ្រីស្ដបរិស័ទ។ ម្យ៉ាងទៀត លិខិតនេះបញ្ជាក់ថា ជំនឿលើព្រះគ្រីស្ដជាព្រះអម្ចាស់ អាចប្រែទំនាក់ទំនងក្នុងសង្គម គឺលោកប៉ូលមិនបង្គាប់លោកភីលេម៉ូនទេ លោកក៏ពុំជំទាស់នឹងសិទ្ធិរបស់លោកភីលេម៉ូន ដែលជាម្ចាស់លើអូនេស៊ីមដែរ លោកគ្រាន់តែរំឭកលោកភីលេម៉ូនថា គ្រីស្ដបរិស័ទជាបងប្អូនគ្នា ព្រោះជាបុត្រធីតារបស់ព្រះបិតា។ ឋានៈរបស់គ្រីស្ដបរិស័ទបង្កើតទំនាក់ទំនងថ្មីរវាងគ្នានឹងគ្នា។

លិខិតរបស់លោកប៉ូល

# ផ្ញើជូនលោកទីតូ

## ពាក្យជម្រាបសួរ

១ខ្ញុំ ប៉ូល ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ និង
១ជាទូតរបស់ព្រះយេស៊ូគ្រីស្ដ*។ ព្រះជាម្ចាស់
ចាត់ខ្ញុំឲ្យនាំអស់អ្នក ដែលព្រះអង្គបានជ្រើស
រើសឲ្យមានជំនឿ និងស្គាល់ច្បាស់នូវសេចក្ដី
ពិត ដែលជាគ្រឹះនៃការគោរពប្រណិប័តន៍ព្រះអ
ង្គ។ ២អ្នកទាំងនោះសង្ឃឹមថានឹងទទួលជីវិត
អស់កល្បជានិច្ច ដែលព្រះជាម្ចាស់បានសន្យា
តាំងពីមុនកាលសម័យទាំងអស់ ព្រះអង្គមិន
កុហកទេ។ ៣នៅពេលកំណត់ព្រះអង្គបាន
សម្តែងព្រះបន្ទូលរបស់ព្រះអង្គ ហើយប្រគល់
ព្រះបន្ទូលនេះ មកឲ្យខ្ញុំប្រកាសតាមបញ្ជារបស់
ព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង។
៤មកដល់ប្អូនទីតូ ជាកូនដ៏ពិតប្រាកដខាង
ជំនឿដែលយើងមានរួមគ្នា។

សូមព្រះជាម្ចាស់ជាព្រះបិតា និងព្រះគ្រីស្ដ
យេស៊ូ ជាព្រះសង្គ្រោះនៃយើងប្រោសប្រណី
និងប្រទានសេចក្ដីសុខសាន្ដដល់ប្អូន។

## កិច្ចការដែលលោកទីតូត្រូវបំពេញ នៅកោះក្រែត

៥ខ្ញុំទុកប្អូនឲ្យនៅកោះក្រែត ដើម្បីចាត់ចែង
កិច្ចការដែលនៅសល់ ឲ្យមានរបៀបរៀបរយ
និងតែងតាំងព្រឹទ្ធាចារ្យ* នៅតាមក្រុងនីមួយៗ
ដូចខ្ញុំបានផ្ដាំរួចហើយ ៦គឺត្រូវយកអ្នកណា
ដែលឥតមានកំហុស ស្រឡាញ់ភរិយាដោយ
ចិត្តស្មោះ[ក] មានកូនចៅជាអ្នកជឿ ហើយគ្មាន
នរណាចោទប្រកាន់ថា ជាកូនខិលខូចមិនចេះ
ស្ដាប់បង្គាប់។ ៧ក្នុងឋានៈជាអ្នកមើលខុសត្រូវ
លើកិច្ចការរបស់ព្រះជាម្ចាស់ អ្នកអភិបាលត្រូវ
តែឥតកំហុស មិនក្រអឺតក្រទម មិនឆាប់ខឹង
មិនចំណូលស្រា មិនចេះឈ្លោះប្រកែក ឬរក
ប្រាក់តាមរបៀបថោកទាបនោះឡើយ។ ៨ផ្ទុយ
ទៅវិញ គាត់ត្រូវចេះទទួលភ្ញៀវ ស្រឡាញ់អំពើ
ល្អ មានចិត្តធ្ងន់ សុចរិត ចិត្តបរិសុទ្ធ* ចេះទប់
ចិត្ត ៩ជាប់ចិត្តនឹងព្រះបន្ទូល ជាគ្រឹះនៃជំនឿ
ស្របតាមសេចក្ដីដែលគេបានរៀន ដើម្បីឲ្យ
មានសមត្ថភាពដាស់តឿនអ្នកដទៃ តាមសេចក្ដី
បង្រៀនដ៏ត្រឹមត្រូវ ព្រមទាំងចេះរកខុសត្រូវ តប
តនឹងពួកអ្នកប្រឆាំងផង។

១០មានមនុស្សជាច្រើន ជាពិសេសក្នុង
ចំណោមសាសន៍យូដាដែលជាអ្នកជឿ មានចិត្ត
រឹងរូស ព្រោកប្រាជ្ញឥតបានការ និងបោកប្រាស
គេទៀតផង។ ១១ត្រូវបំបិទមាត់អ្នកទាំងនោះ
ដ្បិតពួកគេបានធ្វើឲ្យកើតវឹកវរ ក្នុងក្រុមគ្រួសារ
ជាច្រើន ដោយបង្រៀនអំពីសេចក្ដីដែលមិនត្រូវ
បង្រៀន ដើម្បីបោកយកប្រាក់យ៉ាងថោកទាប។

១២មានម្នាក់ក្នុងចំណោមពួកគេ ដែលជាព្យាការី
របស់គេផ្ទាល់ ពោលថា៖ «អ្នកស្រុកក្រែត
សុទ្ធតែជាមេកុហក ជាសត្វតិរច្ឆានដ៏សាហាវ
និងជាមេកម្ជិល ដែលគិតតែពីស៊ីផឹក!»។
១៣ ពាក្យនេះ ពិតណាស់! ដូច្នេះត្រូវស្ដីបន្ទោស
គេយ៉ាងតឹងរ៉ឹង ដើម្បីឲ្យគេមានជំនឿត្រឹមត្រូវ
១៤ កុំឲ្យជាប់ចិត្ត នឹងរឿងព្រេងរបស់សាសន៍យូ
ដា និងជាប់ចិត្តទៅលើបទបញ្ញត្តិ ដែលពួកអ្នក
ងាកចេញពីសេចក្ដីពិត បានតែងនោះឡើយ។
១៥ចំពោះអ្នកដែលមានចិត្តបរិសុទ្ធ អ្វីៗទាំងអស់
សុទ្ធតែបរិសុទ្ធ រីឯអ្នកដែលមានចិត្ត សៅហ្មង
និងមិនជឿអ្វីៗទាំងអស់សុទ្ធតែមិនបរិសុទ្ធ
ព្រោះប្រាជ្ញានិងស្មារតីរបស់គេសុទ្ធតែសៅហ្
ង។ ១៦គេប្រកាសថា ខ្លួនស្គាល់ព្រះជាម្ចាស់
ហើយ ប៉ុន្តែ តាមអំពើដែលគេប្រព្រឹត្ត គេបែរជា
បដិសេធមិនទទួលស្គាល់ព្រះអង្គទៅវិញ។ អ្នក
ទាំងនោះសុទ្ធតែជាមនុស្សគួរឲ្យស្អប់ខ្ពើម ជា
មនុស្សរឹងទទឹងហើយពុំអាចប្រព្រឹត្តអំពើល្អបាន
ឡើយ។

## សេចក្ដីបង្រៀនដ៏ត្រឹមត្រូវ

១ ចំពោះអ្នកវិញ ត្រូវនិយាយតែសេចក្ដីណា
២ដែលស្របតាមសេចក្ដីបង្រៀន ដ៏ត្រឹមត្រូវ។២
ចូរជម្រាបលោកតាចាស់ៗ កុំឲ្យស្រវឹងស្រា ត្រូវ
មានកិរិយាថ្លៃថ្នូរ មានចិត្តធ្ងន់មានជំនឿស្អាតស្អំ
មានចិត្តស្រឡាញ់ និងចេះស៊ូទ្រាំ។
៣រីឯលោកយាយចាស់ៗវិញ ក៏ដូច្នោះដែរ
ចូរជម្រាបគាត់ឲ្យកាន់កិរិយាមារយាទ សមជា
អ្នកដែលមានជីវិតដ៏វិសុទ្ធ* កុំឲ្យនិយាយមួល
បង្កាច់គេ ឬចំណូលស្រាឡើយ។ គាត់ត្រូវចេះ
ផ្ដល់យោបល់ល្អៗ ៤ដើម្បីជួយអប់រំស្ត្រីៗដែល
នៅក្មេងឲ្យចេះស្រឡាញ់ស្វាមី និងស្រឡាញ់
កូនរបស់ខ្លួន ៥ឲ្យមានចិត្តធ្ងន់ មានចរិយា
បរិសុទ្ធ យកចិត្តទុកដាក់នឹងកិច្ចការក្នុងផ្ទះ
សំបែង មានចិត្តល្អ គោរពស្វាមីរៀងៗខ្លួន។ ធ្វើ
ដូច្នេះ គ្មាននរណាអាចមួលបង្កាច់ព្រះបន្ទូល
របស់ព្រះជាម្ចាស់បានឡើយ។

៦រីឯពួកយុវជនវិញ ចូរដាស់តឿនគេឲ្យមាន
ចិត្តធ្ងន់គ្រប់វិស័យទាំងអស់។ ៧ចូរប្រព្រឹត្តអំពើ
ល្អ ធ្វើជាគំរូដល់គេ គឺបង្រៀនគេយ៉ាងស្អាតស្អំ
និងថ្លៃថ្នូរ ៨និយាយពាក្យសំដីត្រឹមត្រូវដែលរក
រិះគន់មិនកើត។ ធ្វើដូច្នេះពួកអ្នកប្រឆាំងនឹង
បាក់មុខ ព្រោះគេរកអ្វីនិយាយអាក្រក់ពីយើង
មិនបាន។

៩ចូរប្រាប់បងប្អូន ដែលជាខ្ញុំបម្រើឲ្យស្ដាប់
បង្គាប់ម្ចាស់រៀងៗខ្លួន ក្នុងគ្រប់កិច្ចការទាំងអស់
ត្រូវធ្វើឲ្យម្ចាស់ពេញចិត្តមិនត្រូវជំទាស់នឹងគាត់
១០មិនត្រូវតែបន្លំយកអ្វីពីម្ចាស់ឡើយ ផ្ទុយទៅ
វិញ ត្រូវសម្ដែងចិត្តល្អស្មោះត្រង់ទាំងស្រុងជា
និច្ច ដើម្បីលើកកិត្តិយសសេចក្ដីបង្រៀន អំពី
ព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់យើង ក្នុងគ្រប់
កិច្ចការទាំងអស់។

១១ព្រះជាម្ចាស់បាន សម្ដែងព្រះហឫទ័យ
ប្រោសប្រណីមក ដើម្បីសង្គ្រោះមនុស្សទាំងអ
ស់។ ១២ព្រះហឫទ័យប្រោសប្រណីនេះអប់រំ
យើងឲ្យលះបង់ចិត្ត ដែលមិនចេះគោរព
ប្រណិប័តន៍ព្រះជាម្ចាស់ចោល ឲ្យលះបង់
សេចក្ដីប៉ងប្រាថ្នាខាងលោកីយ៍ ដើម្បីឲ្យយើង
រស់នៅក្នុងលោកនេះដោយមានចិត្តធ្ងន់ សុចរិត

និងគោរពប្រណិប័តន៍ព្រះជាម្ចាស់ [១៣]ទាំង
ទន្ទឹងរង់ចាំសុភមង្គល តាមសេចក្ដីសង្ឃឹមរបស់
យើងហើយរង់ចាំព្រះយេស៊ូគ្រីស្ដ ជាព្រះជា
ម្ចាស់ដ៏ឧត្ដមបំផុត និងជាព្រះសង្គ្រោះនៃយើង
យាងមកប្រកបដោយសិរីរុងរឿង។ [១៤]ព្រះអង្គ
បានបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់ សម្រាប់
យើងដើម្បីលោះយើង ឲ្យរួចផុតពីអំពើទុច្ចរិត
គ្រប់យ៉ាង និងជម្រះប្រជារាស្ដ្រមួយ ទុក
សម្រាប់ព្រះអង្គផ្ទាល់ ជាប្រជារាស្ដ្រដែលខ្នះ
ខ្នែងប្រព្រឹត្តអំពើល្អ។

[១៥]ប្អូនត្រូវបង្រៀនសេចក្ដីនេះ ទាំងដាស់
តឿន និងស្ដីបន្ទោស ដោយប្រើអំណាចពេញ
ទី។ កុំឲ្យនរណាមើលងាយប្អូនបានឡើយ។

## របៀបរស់នៅរបស់គ្រីស្ដបរិស័ទ

[១]ចូររំលឹកដាស់តឿនបងប្អូន ឲ្យគោរពចុះ
៣ចូលនឹងអាជ្ញាធរ ចុះចូលនឹងរដ្ឋអំណាច ឲ្យ
គេចេះស្ដាប់បង្គាប់ និងប្រុងប្រៀបប្រព្រឹត្តអំពើ
ល្អគ្រប់យ៉ាង។ [២]កុំឲ្យគេនិយាយអាក្រក់ពី
នរណា កុំឲ្យគេបង្ករឿង តែឲ្យគេមានចិត្ត
សប្បុរស និងបង្ហាញចិត្តស្លូតបូតគ្រប់យ៉ាង
ចំពោះមនុស្សទាំងអស់វិញ។ [៣]ពីដើម យើងក៏
ជាមនុស្សឥតដឹងខុសត្រូវ រឹងទទឹង វង្វេងមាគ៌ា
វក់នឹងចំណង់តណ្ហា និងការស្រើបស្រាលគ្រប់
បែបយ៉ាង មានចិត្តកំណាច និងច្រណែន
ឈ្នានីស ជាមនុស្សគួរឲ្យស្អប់ខ្ពើម ព្រមទាំង
ស្អប់គ្នាទៅវិញទៅមកទៀតផង។ [៤]ក៏ប៉ុន្ដែនៅ
ពេលដែលព្រះជាម្ចាស់ ជាព្រះសង្គ្រោះនៃយើង
សម្ដែងព្រះហឫទ័យសប្បុរស និងព្រះហឫទ័យ
ស្រឡាញ់ចំពោះមនុស្សលោក [៥]ព្រះអង្គក៏បាន
សង្គ្រោះយើង តាមព្រះហឫទ័យមេត្ដាករុណា
របស់ព្រះអង្គ គឺមិនមែនមកពីយើងបានប្រព្រឹត្ត
អំពើសុចរិតនោះទេ។ ព្រះអង្គសង្គ្រោះយើង
ដោយលាងជម្រះយើង ឲ្យបានកើតជាថ្មី និង
ប្រទានឲ្យយើងមានជីវិតថ្មី ដោយសារព្រះ
វិញ្ញាណដ៏វិសុទ្ធ។ [៦]ព្រះអង្គចាក់បង្ហូរព្រះ
វិញ្ញាណនេះមកលើយើងយ៉ាងបរិបូណ៌ ដោយ
សារព្រះយេស៊ូគ្រីស្ដ ជាព្រះសង្គ្រោះរបស់យើង
[៧]ដើម្បីឲ្យយើងបានសុចរិត*ដោយសារព្រះ
ហឫទ័យប្រោសប្រណី របស់ព្រះអង្គនិងឲ្យ
យើងបានទទួលជីវិតអស់កល្បជានិច្ច ជាមត៌ក
តាមសេចក្ដីសង្ឃឹមរបស់យើង។ [៨]ពាក្យនេះគួរ
ឲ្យជឿ ខ្ញុំចង់ឲ្យប្អូននិយាយហើយនិយាយទៀត
បញ្ជាក់អំពីសេចក្ដីទាំងនេះដើម្បីឲ្យអស់អ្នក
ដែលជឿលើព្រះជាម្ចាស់ ខិតខំយកចិត្តទុកដាក់
ប្រព្រឹត្តអំពើល្អ។ ការនេះហើយដែលល្អប្រសើរ
និងមានប្រយោជន៍ដល់មនុស្សលោក! [៩]ចូរ
ចៀសវាងការជជែកវែកញែកដ៏លេលា ជជែក
អំពីបញ្ជីវង្សត្រកូល ចៀសវាងទាស់ទែងគ្នា និង
ឈ្លោះប្រកែកគ្នាអំពីធម្មវិន័យ ដ្បិតការទាំងនេះ
ឥតមានផលប្រយោជន៍ ឥតបានការអ្វីទាំងអ
ស់។ [១០]ចំពោះអ្នកដែលបង្កឲ្យមានការបាក់បែក
គ្នា ត្រូវព្រមានគេមួយលើកជាពីរលើក ហើយ
បណ្ដេញគេឲ្យចេញទៅ [១១]ដោយដឹងថា ជន
ប្រភេទនេះជាមនុស្សខូចគេប្រព្រឹត្តអំពើបាប
និងដាក់ទោសខ្លួនឯង។

## ពាក្យបញ្ចប់

[១២]ខ្ញុំចាត់បងអ័រតេម៉ា ឬបងទីឃីគុ ឲ្យមករក

ប្អូន។ កាលណាគាត់មកដល់ ចូរលៃលកទៅរក
ខ្ញុំនៅក្រុងនីកូប៉ូលីកុំបីខាន ដ្បិតខ្ញុំបានសម្រេច
ចិត្តថា នឹងស្នាក់នៅទីនោះក្នុងរដូវត្រជាក់។
១៣ ចូរលៃលកផ្គត់ផ្គង់បងមេធាវីសេណា និង
បងអប៉ូឡូ ឲ្យបន្តដំណើរទៅផង កុំឲ្យលោក
ទាំងពីរខ្វះខាតអ្វីឡើយ។ ១៤ត្រូវឲ្យបងប្អូន
យើងរៀនធ្វើអំពើល្អ ឲ្យបានប្រសើរលើសគេ
ដើម្បីជួយផ្គត់ផ្គង់សេចក្ដី ត្រូវការដ៏ចាំបាច់ផ្សេ
ងៗ កុំឲ្យគេទៅជាមនុស្សមិនបង្កើតផល។

១៥បងប្អូនទាំងអស់ដែលនៅជាមួយខ្ញុំ សូម
ជម្រាបសួរមកប្អូន។ សូមជម្រាបសួរបងប្អូនរួម
ជំនឿដ៏ជាទីស្រឡាញ់របស់យើងផង។

សូមព្រះជាម្ចាស់ប្រោសប្រណី បង
ប្អូនទាំងអស់គ្នា។

# លិខិតទី១ របស់គ្រីស្ត
# ទូតប៉ូល
# ផ្ញើជូនលោកធីម៉ូថេ

## ពាក្យជម្រាបសួរ

១ខ្ញុំប៉ូល ជាគ្រីស្តទូតរបស់ព្រះគ្រីស្តយេស៊ូ
១តាមបញ្ជារបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះនៃ
យើង និងតាមបញ្ជារបស់ព្រះគ្រីស្តយេស៊ូជាទី
សង្ឃឹមនៃយើង ២មកដល់ធីម៉ូថេ[ក] ជាកូនដ៏ពិត
ប្រាកដរបស់ខ្ញុំខាងជំនឿ។ សូមព្រះជាម្ចាស់ជា
ព្រះបិតានិងព្រះគ្រីស្តយេស៊ូជាព្រះអម្ចាស់នៃ
យើង ប្រោសប្រណី មេត្តាករុណា និងប្រទាន
សេចក្ដីសុខសាន្តដល់ប្អូន។

## ពាក្យដាស់តឿនឲ្យប្រយ័ត្ន

៣ពេលខ្ញុំចេញដំណើរទៅស្រុកម៉ាសេដូន ខ្ញុំ
បានផ្ដែផ្ដាំប្អូនថា ចូរស្នាក់នៅក្រុងអេភេសូនេះ
ដើម្បីហាមប្រាមអ្នកខ្លះ កុំឲ្យបង្រៀនសេចក្ដី
ណាផ្សេងទៀតឡើយ ៤ហើយក៏កុំឲ្យជាប់ចិត្ត
ទៅលើរឿងព្រេង និងទៅលើបញ្ជីវង្សត្រកូលដ៏
វែងអន្លាយនោះដែរ។ រឿងទាំងនេះនាំឲ្យតែ
មានការជជែកឥតប្រយោជន៍ ជាជាងបង្ហាញ
អំពីរបៀប ព្រះជាម្ចាស់សង្គ្រោះមនុស្សលោក
ដោយសារជំនឿ។ ៥ហេតុដែលខ្ញុំឲ្យហាមប្រាម
ដូច្នេះ គឺក្នុងគោលបំណងចង់ឲ្យគេមានសេចក្ដី
ស្រឡាញ់មកពីចិត្តបរិសុទ្ធ* មកពីស្មារតីល្អ
និងមកពីជំនឿឥតពុតត្បុត។ ៦អ្នកខ្លះបានងាក
ចេញពីគោលការណ៍នេះ ហើយក៏ត្រូវវង្វេង
វង្វាន់ បែរទៅនិយាយពាក្យសំដីឥតខ្លឹមសារ
៧ គេចង់តាំងខ្លួនជាធម្មាចារ្យ តែគេមិនយល់
ទាំងពាក្យដែលខ្លួននិយាយ ទាំងសេចក្ដីដែល
ខ្លួនបញ្ជាក់ថាពិតនោះផង។

៨យើងដឹងហើយថា ធម្មវិន័យ*ល្អប្រសើរ
លុះត្រាតែយើងប្រើធម្មវិន័យ ដើម្បីឲ្យស្គាល់
អំពើល្អអំពើអាក្រក់។ ៩យើងតោងដឹងទៀតថា
ធម្មវិន័យ មិនមែនចែងទុកសម្រាប់មនុស្ស

សុចរិត*ទេ គឺសម្រាប់មនុស្សល្មើសបទវិន័យ
មនុស្សមិនស្ដាប់បង្គាប់មនុស្ស មិនគោរព
ប្រណិប័តន៍ព្រះជាម្ចាស់ មនុស្សបាប ពួកអ្នក
បំផ្លាញនិងប្រមាថទីសក្ការៈ ពួកអ្នកសម្លាប់
ឪពុកម្ដាយ សម្លាប់គេ ១០ពួកប្រាសចាកសីល
ធម៌ ពួករួមសង្វាសនឹងភេទដូចគ្នា ពួកឈ្មួញ
មនុស្ស ពួកកុហក ពួកស្បថ បំពាន និង ពួកអ្នក
ដែលប្រព្រឹត្តអ្វីៗ ប្រឆាំងនឹងសេចក្ដីប្រៀន
ប្រដៅដ៏ត្រឹមត្រូវ ១១ស្របតាមដំណឹងល្អស្ដីអំពី
ព្រះជាម្ចាស់ប្រកបដោយសិរីរុងរឿង និងសុភ
មង្គលជាដំណឹងល្អ ដែលព្រះអង្គបានផ្ញើទុកនឹង
ខ្ញុំ។

## ព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់

១២ខ្ញុំសូមអរព្រះគុណ ព្រះគ្រីស្ដយេស៊ូជា
អម្ចាស់នៃយើង ដែលបានប្រទានកម្លាំងមកខ្ញុំ
ទ្រង់បានរាប់ខ្ញុំជាមនុស្សគួរឲ្យទុកចិត្ត ហើយ
តែងតាំងខ្ញុំឲ្យបម្រើព្រះអង្គ។ ១៣ទោះបីពីដើមខ្ញុំ
ធ្លាប់ប្រមាថបៀតបៀន និងប្រព្រឹត្តអំពើ
ឃោរឃៅក៏ដោយ ក៏ព្រះអង្គមានព្រះហឫទ័យ
មេត្តាករុណាដល់ខ្ញុំដែរ ព្រោះកាលណោះខ្ញុំ
គ្មានជំនឿ ហើយមិនយល់កិច្ចការដែលខ្ញុំ
ប្រព្រឹត្ត។ ១៤ប៉ុន្តែ ព្រះអម្ចាស់នៃយើងមានព្រះ
ហឫទ័យប្រោសប្រណីខ្ញុំ ច្រើនពន់ប្រមាណ
ទ្រង់ប្រោសប្រទានឲ្យខ្ញុំមានជំនឿ និងមាន
សេចក្ដីស្រឡាញ់ ដោយរួមក្នុងអង្គព្រះគ្រីស្ដយេ
ស៊ូ។ ១៥ពាក្យនេះគួរឲ្យជឿហើយសមនឹង
ទទួលយកទាំងស្រុង គឺថាព្រះគ្រីស្ដយេស៊ូបាន
យាងមកក្នុងពិភពលោក ដើម្បីសង្គ្រោះមនុស្ស
បាបដូចរូបខ្ញុំនេះជាអាទិ។ ១៦ព្រះជាម្ចាស់ទ្រង់
មានព្រះហឫទ័យមេត្តា ករុណា ចំពោះខ្ញុំដូច្នេះ
ដើម្បីឲ្យព្រះគ្រីស្ដយេស៊ូ សម្ដែងព្រះហឫទ័យ
អត់ធ្មត់គ្រប់ចំពូក ដល់ខ្ញុំមុនគេ ទុកជា
ឧទាហរណ៍សម្រាប់អស់អ្នក ដែលនឹងជឿលើ
ព្រះអង្គ ហើយទទួលជីវិតអស់កល្បជានិច្ច។

១៧សូមឲ្យព្រះមហាក្សត្រ ដែលគ្រងរាជ្យ
គ្រប់កល្បជាព្រះជាម្ចាស់តែមួយព្រះអង្គ មាន
ព្រះជន្មមិនចេះសាបសូន្យ ដែលមនុស្សមើលពុំ
ឃើញ បានប្រកបដោយព្រះកិត្តិនាម និងសិរី
រុងរឿងអស់កល្បជាអង្វែងតរៀងទៅ! អាម៉ែន!

១៨ធីម៉ូថេកូនអើយ! ខ្ញុំផ្ដាំផ្ញើមកដូច្នេះ ស្រប
តាមពាក្យដែលគេបានអធិដ្ឋានលើកូន។ សូម
ពឹងលើពាក្យទាំងនេះ ដើម្បីពុះពារតយុទ្ធឲ្យ
បានល្អប្រសើរ ១៩ដោយមានជំនឿនិងមានមាន
ស្មារតីនឹងន។ អ្នកខ្លះលះបង់ស្មារតីល្អបែបនេះ
បណ្ដាលឲ្យជំនឿរបស់គេលិចលង់។ ២០ក្នុង
ចំណោមអ្នកទាំងនោះ មានហ៊ីមេណា និងអ
ឡិចសង់ជាដើម។ ខ្ញុំបានប្រគល់ពួកគេទៅក្នុង
កណ្ដាប់ដៃរបស់មារសាតាំង ដើម្បីឲ្យគេរៀន
ឈប់ប្រមាថព្រះជាម្ចាស់ទៀត។

## ពាក្យទូន្មានក្នុងការទូលអង្វរព្រះជាម្ចាស់

១ជាបឋម ខ្ញុំសូមផ្ដែផ្ដាំឲ្យទូលសូមព្រះជា
២ម្ចាស់ អធិដ្ឋាន*និងអង្វរព្រះអង្គទាំងអរព្រះ
គុណ សម្រាប់មនុស្សទាំងអស់ផង។ ២សម្រាប់
ស្ដេច និងអ្នកកាន់អំណាចគ្រប់ៗរូប ដើម្បីឲ្យ

យើងរស់នៅបានសុខក្សេមក្សាន្តគ្មានចលាចល
ទាំងគោរពប្រណិប័តន៍ព្រះជាម្ចាស់ អស់ពីចិត្ត
និងមានជីវិតថ្លៃថ្នូរ។ ៣នេះហើយជាការល្អ និង
គាប់ព្រះហឫទ័យព្រះជាម្ចាស់ ជាព្រះសង្គ្រោះ
របស់យើង ៤ដែលទ្រង់សព្វព្រះហឫទ័យឲ្យ
មនុស្សទាំងអស់បានទទួលការសង្គ្រោះ និង
បានស្គាល់សេចក្ដីពិតយ៉ាងច្បាស់

*៥មានព្រះជាម្ចាស់តែមួយ មានស្ពានមេត្រី
តែមួយរវាងព្រះជាម្ចាស់និងមនុស្សលោក ជា
មនុស្សម្នាក់ គឺព្រះគ្រីស្ដយេស៊ូ។ ៦ព្រះអង្គបាន
បូជាព្រះជន្ម ដើម្បីលោះមនុស្សទាំងអស់។*

នេះជាសក្ខីភាពមួយ ដែលព្រះអង្គបាន
បង្ហាញ នៅពេលកំណត់ ៧ព្រះអង្គបានតែង
តាំងខ្ញុំ ឲ្យប្រកាសសក្ខីភាពនេះ ឲ្យខ្ញុំធ្វើជាគ្រីស្ដ
ទូត* ព្រមទាំងធ្វើជាគ្រូអប់រំសាសន៍ដទៃអំពី
ជំនឿ និងអំពីសេចក្ដីពិត។ ខ្ញុំនិយាយពិតឥត
កុហកទេ។

៨ហេតុនេះហើយ បានជានៅគ្រប់ទីកន្លែងខ្ញុំ
ចង់ឲ្យបុរសៗអធិដ្ឋាន*ទាំងលើកដៃឡើងលើ
ដោយចិត្តបរិសុទ្ធ ឥតមានកំហឹង ឬប្រកែកគ្នា
ឡើយ។

៩ខ្ញុំក៏ចង់ឲ្យស្ត្រីៗស្លៀកពាក់ បែបសមរម្យ
រាបសា មិនសង្ហារ។ នាងមិនត្រូវតែងខ្លួនដោយ
ក្រងសក់ឲ្យឆើតឆាយហួស ឬដោយពាក់មាស
ពេជ្រ និងគ្រឿងអលង្ការថ្លៃៗឡើយ ១០តែត្រូវតុ
បតែងខ្លួន ដោយអំពើល្អឲ្យបានសមរម្យ ជាស្ត្រី
ដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់វិញ។ ១១
នៅពេលរៀន ស្ត្រីៗត្រូវនៅស្ងៀម ហើយស្ដាប់
បង្គាប់ទាំងស្រុង។ ១២ខ្ញុំមិនអនុញ្ញាតឲ្យស្ត្រីណា
បង្រៀន ឬត្រួតត្រាលើប្ដីឡើយ គឺឲ្យនាងនៅ
ស្ងៀមវិញ ១៣ដ្បិតព្រះជាម្ចាស់បានសូនលោក
អដាំជាមុន រួចបង្កើតនាងអេវ៉ាតាមក្រោយ។ ១៤
មិនមែនលោកអដាំទេដែលចាញ់បោកមារ គឺ
នាងអេវ៉ាវិញទេតើដែលចាញ់បោកហើយ
រំលោភលើបញ្ញត្តិ របស់ព្រះជាម្ចាស់ទៀតផង។
១៥ក៏ប៉ុន្តែ ព្រះអង្គសង្គ្រោះស្ត្រីមកពីនាងបង្កើត
កូន លុះត្រាតែនាងមានជំនឿខ្ជាប់ខ្ជួនមានចិត្ត
ស្រឡាញ់ មានកិរិយាវិសុទ្ធ* និងសុភាព
រាបសាផង។

## អ្នកដឹកនាំព្រះសហគមន៍

១ពាក្យនេះគួរឲ្យជឿ គឺថាប្រសិនបើបងប្អូន
៣ណាម្នាក់ ចង់បានមុខងារជាអភិបាលគាត់
មានបំណងបំពេញមុខងារ ដ៏ប្រសើរហើយ។
២អ្នកអភិបាល ត្រូវមានគុណសម្បត្តិល្អឥតខ្ចោះ
ត្រូវមានភរិយាតែមួយប៉ុណ្ណោះ[ខ] មិនស្រវឹងស្រា
មានចិត្តធ្ងន់ មានកិរិយាមារយាទល្អ ចេះទទួល
ភ្ញៀវ ចេះបង្រៀន ៣មិនចំណូលស្រា មិនចេះ
ឈ្លោះប្រកែក គឺមានចិត្តសប្បុរស មិនចេះរក
រឿង មិនស្រឡាញ់ប្រាក់ឡើយ។ ៤គាត់ត្រូវចេះ
មើលខុសត្រូវ លើក្រុមគ្រួសាររបស់គាត់ផ្ទាល់
ព្រមទាំងឲ្យកូនចៅរបស់គាត់ ចេះស្ដាប់បង្គាប់
និងមានកិរិយាថ្លៃថ្នូរទាំងស្រុង ៥ព្រោះថា
ប្រសិនបើមនុស្សម្នាក់ មិនចេះមើលខុសត្រូវលើ
ក្រុមគ្រួសាររបស់ខ្លួនផង ធ្វើម្ដេចនឹងឲ្យគាត់
មើលខុសត្រូវលើព្រះសហគមន៍* របស់ព្រះជា
ម្ចាស់កើត!។ ៦មិនត្រូវឲ្យអ្នកដែលទើបនឹងជឿ
ធ្វើជាអភិបាលឡើយ ក្រែងលោគាត់អួតបំប៉ោង
ហើយទៅជាមានទោសដូចមារ*។ ៧មួយវិញ

ទៀត អ្នកអភិបាលត្រូវតែមានកេរ្តិ៍ឈ្មោះល្អ ពី
សំណាក់អស់អ្នក ដែលនៅក្រៅព្រះសហគមន៍
ផងដែរ ក្រែងគេប្រមាថមើលងាយ ហើយគាត់
ធ្លាក់ទៅក្នុងអន្ទាក់របស់មារ។

## ឧបដ្ឋាក

៨រីឯឧបដ្ឋាក*វិញ ក៏ដូច្នោះដែរត្រូវតែមាន
កិរិយាថ្លៃថ្នូរនិយាយពាក្យសច្ចៈមិនចំណូលស្រា
ជ្រុល មិនរកប្រាក់តាមរបៀបថោកទាប។ ៩គាត់
ត្រូវកាន់តាមជំនឿ ដែលព្រះជាម្ចាស់បាន
សម្តែងមក[គ] ដោយស្មារតីបរិសុទ្ធ។ ១០ត្រូវល្បង
មើលចិត្តគេជាមុនសិន ប្រសិនបើមិនឃើញ
មានទាស់ត្រង់ណាទេនោះ ទុកឲ្យគេបំពេញមុខ
ងារជាឧបដ្ឋាកទៅចុះ។

១១ចំពោះឧបដ្ឋាយិកាវិញ[ឃ] ក៏ដូច្នោះដែរ
ត្រូវតែមានកិរិយាថ្លៃថ្នូរ មិនចេះនិយាយដើមគេ
មិនស្រវឹងស្រា និងមានចិត្តស្មោះត្រង់ក្នុងគ្រប់
កិច្ចការទាំងអស់។

១២ឧបដ្ឋាកត្រូវស្រឡាញ់ភរិយា ដោយចិត្ត
ស្មោះ[ង] ហើយចេះមើលខុសត្រូវកូនចៅ និង
ក្រុមគ្រួសាររបស់ខ្លួនឯងផ្ទាល់ផង ១៣ដ្បិតបង
ប្អូនណាបំពេញមុខងារជាឧបដ្ឋាកបានល្អ នឹង
បានទទួលកិត្តិយស ព្រមទាំងមានចិត្តអង់អាច
មុះមុតដោយអាងលើជំនឿ ក្នុងអង្គព្រះគ្រីស្ត
យេស៊ូ។

## លទ្ធិដ៏អស្ចារ្យ

១៤ខ្ញុំសរសេរសេចក្ដីទាំងនេះ ទាំងសង្ឃឹមថា
នឹងបានមកជួបប្អូនក្នុងពេលឆាប់ៗ ១៥ក៏ប៉ុន្តែបើ
ខ្ញុំក្រមកដល់ សេចក្ដីទាំងនេះនឹងជួយអ្នកឲ្យដឹង
របៀបដែលត្រូវប្រព្រឹត្ត ក្នុងព្រះដំណាក់របស់
ព្រះជាម្ចាស់ គឺក្នុងព្រះសហគមន៍*របស់ព្រះដ៏
មានព្រះជន្មគង់នៅ។ ព្រះសហគមន៍នេះជា
សសរនិងជាគ្រឹះទ្រទ្រង់សេចក្ដីពិត។ ១៦លទ្ធិដ៏
អស្ចារ្យនៃសាសនាយើង ពិតជាប្រសើរណាស់
គឺថា៖

*ព្រះជាម្ចាស់បានសម្តែងការសង្គ្រោះ*
*ដោយសារព្រះគ្រីស្តក្នុងឋានៈជាមនុស្ស*
*ព្រះវិញ្ញាណប្រោសព្រះគ្រីស្តឲ្យបានសុចរិត**
*ព្រះគ្រីស្តសម្តែងព្រះអង្គឲ្យក្រុមអ្នកនាំសារ*
*ឃើញ អស់លោកប្រកាសដំណឹងល្អអំពីព្រះគ្រី*
*ស្តក្នុងចំណោមជាតិសាសន៍នានា*
*មនុស្សក្នុងពិភពលោកបានជឿលើព្រះអង្គ*
*ព្រះជាម្ចាស់លើកព្រះគ្រីស្តឡើង*
*ឲ្យរួមក្នុងសិរីរុងរឿងរបស់ព្រះអង្គ។*

## គ្រូក្លែងក្លាយ

១ព្រះវិញ្ញាណ មានព្រះបន្ទូលយ៉ាងច្បាស់ថា
៤នៅគ្រាចុងក្រោយនឹងមានអ្នកខ្លះបោះបង់
ចោលជំនឿ ទៅជាប់ចិត្តនឹងវិញ្ញាណបោក
បញ្ឆោត ហើយទៅជាប់ចិត្តនឹងសេចក្ដីប្រៀន
ប្រដៅរបស់អារក្សវិញ។ ២គេនឹងចាញ់បោកពុត
ត្បុត របស់មេបោកប្រាស់។ ស្មារតីរបស់អ្នក
ទាំងនោះ ជាប់ជាខ្ញុំបម្រើរបស់អារក្ស[ច]។ ៣ពួក
គេនឹងហាមប្រាមមិនឲ្យយកប្តីប្រពន្ធ មិនឲ្យ
បរិភោគអាហារខ្លះ ដែលព្រះជាម្ចាស់បាន
ប្រតិស្ឋានមក ដើម្បីឲ្យអ្នកជឿ ដែលស្គាល់
សេចក្ដីពិតយ៉ាងច្បាស់បរិភោគទាំងអរព្រះគុណ

ផង។ ៤សត្វលោកទាំងអស់ដែលព្រះជាម្ចាស់
បានប្រតិស្ឋានមក សុទ្ធតែល្អទាំងអស់។
ប្រសិនបើយើងទទួលទានទាំងអរព្រះគុណវិញ
មិនត្រូវចោលអាហារណាមួយឡើយ ៥ដ្បិតព្រះ
បន្ទូលរបស់ព្រះជាម្ចាស់ និងពាក្យអធិដ្ឋាន ធ្វើ
ឲ្យអាហារទាំងអស់ទៅជាវិសុទ្ធហើយ។

## អ្នកបម្រើដ៏ល្អរបស់ព្រះអម្ចាស់

៦ចូរយកសេចក្តីទាំងនេះទៅពន្យល់បងប្អូន
ទើបបងប្អូនពិតជាបម្រើព្រះគ្រីស្តយេស៊ូយ៉ាងល្អ
ប្រសើរ ស្របតាមពាក្យនៃជំនឿ និងសេចក្តី
បង្រៀនដ៏ល្អ ដែលបងប្អូនបានរៀនយ៉ាងដិត
ដល់នោះមែន។ ៧កុំលះបង់រឿងព្រេងដ៏ឥតខ្លឹម
សាររបស់យាយចាស់ៗចោលចេញ ហើយត្រូវ
បែរមក ហាត់គោរពប្រណិប័តន៍ព្រះជាម្ចាស់វិ
ញ។ ៨ការហាត់ប្រាណមានប្រយោជន៍តែបន្តិច
បន្តួចប៉ុណ្ណោះ រីឯការគោរពប្រណិប័តន៍ព្រះជា
ម្ចាស់វិញ មានប្រយោជន៍គ្រប់ជំពូកទាំងអស់
ហើយផ្តល់ជីវិតនាបច្ចុប្បន្នកាល និងជីវិតទៅ
អនាគតកាល តាមព្រះបន្ទូលសន្យា។៩ ពាក្យ
ដូចតទៅនេះគួរឲ្យជឿ សមនឹងទទួលយកទាំង
ស្រុង គឺថា៖ ១០យើងធ្វើការនឿយហត់ យើងខំ
ប្រឹងតយុទ្ធ មកពីយើងសង្ឃឹមលើព្រះជាម្ចាស់ដ៏
មានព្រះជន្មគង់នៅ ព្រះអង្គជាព្រះសង្គ្រោះ
របស់មនុស្សលោកទាំងអស់ ជាពិសេសរបស់
អ្នកជឿ។ ១១ប្អូនត្រូវដាស់តឿននិងបង្រៀន
សេចក្តីទាំងនេះ។ ១២កុំបណ្តោយឲ្យនរណា
មើលងាយប្អូន ព្រោះប្អូននៅក្មេង ផ្ទុយទៅវិញ
ក្នុងការនិយាយស្តីក្តី កិរិយាមារយាទក្តីចិត្ត
ស្រឡាញ់ក្តី ជំនឿក្តី និងចិត្តបរិសុទ្ធក្តីត្រូវធ្វើជា
គំរូដល់អស់អ្នកជឿ។

១៣ចូរយកចិត្តទុកដាក់អានគម្ពីរ យកចិត្ត
ទុកដាក់ដាស់តឿន និងបង្រៀនបងប្អូនកុំខាន
ទម្រាំខ្ញុំមកដល់។ ១៤កុំធ្វេសប្រហែសនឹងព្រះ
អំណោយទានដែលស្ថិតនៅក្នុងប្អូន គឺជាព្រះ
អំណោយទានដែលប្អូនបានទទួល នៅពេលគេ
បានអធិដ្ឋានឲ្យប្អូន និងដោយក្រុមអាចារ្យ*
បានដាក់ដៃ*លើប្អូន ១៥ត្រូវយកចិត្តទុកដាក់
បំពេញមុខងារនេះ និងព្យាយាមតទៅមុខទៀត
ដើម្បីឲ្យគ្រប់គ្នាឃើញថា ប្អូនពិតជាចម្រើន
ឡើងមែន។ ១៦ត្រូវប្រយ័ត្នលើខ្លួនឯង ប្រយ័ត្ន
នឹងសេចក្តីដែលប្អូនបង្រៀន។ ដោយព្យាយាម
ធ្វើដូច្នេះប្អូននឹងសង្គ្រោះទាំងខ្លួនប្អូនផង ទាំង
បងប្អូនដែលស្តាប់ប្អូនផង។

## ដំបូន្មានស្តីអំពីការមើលខុសត្រូវលើអ្នកជឿ

១ចំពោះមនុស្សចាស់ កុំស្តីបន្ទោសតឹងរ៉ឹងពេក
៥តែត្រូវទូន្មានគាត់ទុកដូចជាឪពុក ត្រូវទូន្មាន
ក្មេងៗទុកដូចជាប្អូន ២ទូន្មានស្ត្រីចាស់ៗទុកដូច
ជាម្តាយ និងស្ត្រីក្មេងៗទុកដូចជាប្អូនស្រីដោយ
ចិត្តបរិសុទ្ធទាំងស្រុង។

៣ត្រូវជួយស្ត្រីមេម៉ាយធណា ដែលគ្មានទីពឹង
ធ។ ៤ប្រសិនបើស្ត្រីមេម៉ាយណាមានកូន ឬមាន
ចៅ ត្រូវឲ្យកូនចៅទាំងនោះរៀនបំពេញករណី
យកិច្ចរបស់ខ្លួនចំពោះក្រុមគ្រួសារ និងចេះសង
គុណឪពុកម្តាយ នេះជាការដែលគាប់ព្រះ
ហឫទ័យព្រះជាម្ចាស់។ ៥ចំពោះស្ត្រីមេម៉ាយ
ណាដែលគ្មានទីពឹង រស់នៅតែម្នាក់ឯងស្ត្រី

មេម៉ាយនោះសង្ឃឹមលើព្រះជាម្ចាស់ ហើយ
ព្យាយាមទូលអង្វរ និងអធិដ្ឋាន*ទាំងយប់ទាំង
ថ្ងៃ។ ៦រីឯស្ត្រីមេម៉ាយណាដែលគិតតែពីស្រើប
ស្រាល ថ្វីដ្បិតតែនៅរស់ក៏ដោយក៏ហាក់ដូចជា
ស្លាប់ដែរ។ ៧ប្អូនត្រូវដាស់តឿននាង តាម
សេចក្ដីទាំងនេះ ដើម្បីកុំឲ្យនាងមានកំហុស។
៨អ្នកណាមិនរវល់ថែទាំសាច់ញាតិរបស់ខ្លួន ជា
ពិសេសមិនថែទាំអ្នក ដែលនៅក្នុងក្រុមគ្រួសារ
របស់ខ្លួនផ្ទាល់ អ្នកនោះបានក្បត់ជំនឿរបស់ខ្លួន
ហើយអាក្រក់ជាងអ្នកមិនជឿទៅទៀត។

៩ស្ត្រីដែលអ្នកត្រូវរាប់បញ្ចូល ទៅក្នុងបញ្ជី
ស្ត្រីមេម៉ាយ តោងមានអាយុពីហុកសិបឆ្នាំឡើង
ទៅ ហើយធ្លាប់មានប្ដីតែមួយប៉ុណ្ណោះ។ ១០គាត់
ត្រូវមានឈ្មោះថាបានប្រព្រឹត្តអំពើល្អ គឺបាន
អប់រំចិញ្ចឹមកូនចៅ បានទទួលភ្ញៀវ បានលាង
ជើងជូនជនដ៏វិសុទ្ធ* បានជួយធុរៈអ្នកដែល
មានទុក្ខលំបាក និងយកចិត្តទុកដាក់ប្រព្រឹត្ត
អំពើល្អសព្វបែបយ៉ាង។

១១ចំពោះស្ត្រីមេម៉ាយដែលនៅក្មេងវិញ កុំ
ចុះក្នុងបញ្ជីឡើយ ដ្បិតនៅពេលដែលនាង
ស្រើបស្រាលចង់បានប្ដីទៀតនោះ នាងមុខជា
ដាច់ចេញពីព្រះគ្រីស្ដមិនខាន ១២ហើយ
បណ្ដាលឲ្យខ្លួនមានទោស ដោយផ្ដាច់ពាក្យ
ដែលខ្លួនបានសន្យាពីមុននោះ។ ១៣ម្យ៉ាងវិញ
ទៀត ពួកនាងមិនធ្វើការអ្វីទេ គឺមានទម្លាប់ដើរ
ពីផ្ទះមួយទៅផ្ទះមួយ។ ពួកនាងមិនគ្រាន់តែអត់
ធ្វើអ្វីប៉ុណ្ណោះទេ គឺថែមទាំងនិយាយប៉ប៉ាច់
ប៉ប៉ោច និយាយបេះបួយ និងនិយាយពីការផ្សេ
ងៗដែលមិនត្រូវនិយាយ។ ១៤ហេតុនេះ ខ្ញុំចង់
ឲ្យស្ត្រីមេម៉ាយ ដែលនៅក្មេងរៀបការសាជាថ្មី
ឲ្យមានកូនចៅ និងមើលការខុសត្រូវក្នុងផ្ទះ
របស់ខ្លួន ដើម្បីកុំឲ្យអ្នកប្រឆាំងមានឱកាសចាប់
កំហុសបានឡើយ ១៥ដ្បិតមាននាងខ្លះបាន
ឃ្លាតចាកពីមាគ៌ាល្អ បែរទៅតាមមារ*សាតាំង
រួចទៅហើយ។ ១៦ប្រសិនបើស្ត្រីម្នាក់ជាអ្នកជឿ
មានស្ត្រីមេម៉ាយខ្លះ ក្នុងក្រុមញាតិរបស់គាត់
គាត់ត្រូវជួយទំនុកបម្រុងនាងទាំងនោះផង មិន
ត្រូវទុកឲ្យព្រះសហគមន៍* ពិបាកផ្គត់ផ្គង់នាង
ឡើយ ធ្វើដូច្នេះព្រះសហគមន៍អាចនឹងជួយ
ទំនុកបម្រុងស្ត្រីមេម៉ាយដែលគ្មានទីពឹងវិញ។

១៧អាចារ្យ*ទាំងឡាយណា នាំមុខព្រះ
សហគមន៍យ៉ាងល្អប្រពៃ ត្រូវលើកកិត្តិយស
គាត់ មួយទ្វេជាពីរ[ឈ]ជាពិសេសចំពោះអាចារ្យ
ណាដែលនឿយហត់ប្រកាសព្រះបន្ទូល និង
បង្រៀនគេ ១៨ដ្បិតមានចែងទុកក្នុងគម្ពីរថា «*កុំ
ឃ្លុំមាត់គោ នៅពេលបញ្ជាន់ស្រូវឡើយ*»[ញ]
ហើយ «*កម្មករត្រូវតែទទួលប្រាក់ឈ្នួល*»[ដ]។
១៩បើមានគេចោទប្រកាន់អាចារ្យណាម្នាក់ កុំ
ទទួលពាក្យចោទរបស់គេឲ្យសោះ លើកលែង
តែមានសាក្សីពីរ ឬបីនាក់។ ២០បើមានបងប្អូន
ណាប្រព្រឹត្តអំពើបាប ចូរបន្ទោសអ្នកទាំងនោះ
នៅមុខគេឯងទាំងអស់គ្នា ដើម្បីឲ្យបងប្អូន
ឯទៀតៗខ្លាចដែរ។

២១ខ្ញុំសុំបង្គាប់ប្អូន នៅចំពោះព្រះភក្ត្រព្រះ
ជាម្ចាស់ នៅចំពោះព្រះភក្ត្រព្រះគ្រីស្ដយេស៊ូ
និងនៅចំពោះមុខទេវទូត* ដែលព្រះអង្គបាន
ជ្រើសរើសថា ចូរធ្វើតាមពាក្យដែលខ្ញុំផ្ដែផ្ដាំទាំង
នេះ ដោយឥតកាន់ជើង ឬរើសមុខបងប្អូនណា

ឡើយ។ ២២កុំប្រញាប់ដាក់ដៃតែងតាំងអ្នកណា
ម្នាក់ពេក ដើម្បីកុំឲ្យចូលរួមក្នុងអំពើបាបរបស់
អ្នកនោះ។ ចូររក្សាខ្លួនឲ្យបានបរិសុទ្ធ*។ ២៣
ដោយប្អូនមានជំងឺជាញឹកញាប់ កុំពិសាតែទឹក
ទៀតឡើយចូរពិសាស្រាខ្លះៗផងទៅ ដើម្បីឲ្យ
ស្រានោះជួយរំលាយអាហារ។ ២៤អំពើបាប
របស់អ្នកខ្លះ បានលេចមកឲ្យគេឃើញច្បាស់
មុនពេលវិនិច្ឆ័យទោស តែអំពើបាបរបស់អ្នកខ្លះ
ទៀតនឹងលេចមកនៅពេលក្រោយ។ ២៥រីឯអំពើ
ល្អក៏នឹងលេចមក ឲ្យគេឃើញយ៉ាងច្បាស់
ដូច្នោះដែរ ហើយសូម្បីតែអំពើល្អដែលមិនទាន់
លេចមក ក៏ពុំអាចនៅលាក់កំបាំងបានឡើយ។

១ចំពោះបងប្អូនដែលជាទាសករ ត្រូវគោរព
៦ម្ចាស់របស់ខ្លួន ទុកដូចជាមនុស្ស ដែលសម
នឹងទទួលកិត្តិយសគ្រប់យ៉ាង ដើម្បីកុំឲ្យនរណា
ម្នាក់និយាយមួលបង្កាច់ព្រះនាម នៃព្រះជា
ម្ចាស់ និងមួលបង្កាច់សេចក្ដីបង្រៀនរបស់យើង
បានឡើយ។ ២បងប្អូនទាំងឡាយណាមាន
ម្ចាស់ជាអ្នកជឿ មិនត្រូវធ្វេសប្រហែសក្នុងការ
គោរពគាត់ ដោយយល់ថា គាត់ជាបងប្អូននោះ
ឡើយ ផ្ទុយទៅវិញ ត្រូវបម្រើម្ចាស់ទាំងនោះឲ្យ
រឹតតែប្រសើរឡើងថែមទៀត ដោយយល់ថា
អ្នកដែលទទួលការបម្រើដ៏ល្អនេះ គឺជាអ្នកជឿ
និងជាបងប្អូនដ៏ជាទីស្រឡាញ់។

## អំពីសេចក្ដីបង្រៀនក្លែងក្លាយ

ប្អូនត្រូវបង្រៀន និងដាស់តឿនគេតាម
សេចក្ដីទាំងនេះ។ ៣ប្រសិនបើមាននរណាម្នាក់
បង្រៀនសេចក្ដីណាផ្សេងទៀត ហើយមិនយក
ចិត្តទុកដាក់នឹងព្រះបន្ទូល ដ៏ត្រឹមត្រូវរបស់ព្រះ
យេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង និងមិនយក
ចិត្តទុកដាក់នឹងសេចក្ដីបង្រៀន ស្របតាមការ
គោរពប្រណិប័តន៍ព្រះជាម្ចាស់ទេនោះ ៤អ្នក
នោះជាមនុស្សអួតបំប៉ោងគ្មានដឹងអ្វីទាំងអស់។
គេដូចជាមានជំងឺ ចេះតែជជែកវែកញែក និង
ឈ្លោះប្រកែកអំពីពាក្យពេចន៍។ ការទាំងនេះ
បង្កឲ្យតែមានការច្រណែនឈ្នានីស ការបាក់
បែក ការជេរប្រមាថ ការមិនទុកចិត្តគ្នា ៥និងនាំ
ឲ្យអស់អ្នកដែលមានគំនិតខូច គ្មានសេចក្ដីពិត
ក្នុងខ្លួន ជជែកតវ៉ាមិនចេះចប់មិនចេះហើយ។
ពួកគេចាត់ទុកថា ការគោរពប្រណិប័តន៍ព្រះជា
ម្ចាស់ជាមធ្យោបាយរកទ្រព្យសម្បត្តិ។ ៦ចំពោះ
អ្នកដែលចេះស្កប់ចិត្តនឹងអ្វីដែលខ្លួនមាន ការ
គោរពប្រណិប័តន៍ព្រះជាម្ចាស់ ពិតជាមធ្យោ
បាយដ៏ប្រសើរ ដើម្បីរកទ្រព្យសម្បត្តិមែន! ៧
ដ្បិតយើងពុំបានយកអ្វី ចូលមកក្នុងលោកនេះ
ហើយយើងក៏ពុំអាចយកអ្វី ចេញពីលោកនេះ
ទៅបានដែរ!។ ៨ដូច្នេះប្រសិនបើយើងមានម្ហូប
អាហារ មានសម្លៀកបំពាក់នោះ យើងស្កប់ចិត្ត
ហើយ។ ៩រីឯអស់អ្នកដែលចង់មាន ចង់បាន
រមែងតែងតែចាញ់ការល្បួង ជាប់អន្ទាក់ ដោយ
ចិត្តំណងតណ្ហាដ៏លេលា និងចង្រៃជាច្រើន
ដែលពន្លិចមនុស្សឲ្យវិនាសអន្តរាយ ១០ដ្បិតការ
ស្រឡាញ់ប្រាក់ ជាឫសគល់នៃអំពើអាក្រក់គ្រប់
បែបយ៉ាង។ ដោយបណ្ដោយខ្លួនឲ្យស្រឡាញ់
ប្រាក់ដូច្នេះ បងប្អូនខ្លះបានវង្វេងចេញឆ្ងាយពី
ជំនឿ ព្រមទាំងធ្វើបាបខ្លួនឯងឲ្យវេទនា ឈឺផ្សា
ជាច្រើនថែមទៀតផង។

## ពាក្យដាស់តឿនចុងបញ្ចប់

[១១]ចំពោះប្អូន ជាអ្នកបម្រើរបស់ព្រះជាម្ចាស់វិញ ត្រូវគេចចេញពីការទាំងនេះ។ ចូរស្វែងរកសេចក្ដីសុចរិត ការគោរពប្រណិប័តន៍ព្រះជាម្ចាស់ ជំនឿ សេចក្ដីស្រឡាញ់ ចិត្តអត់ធ្មត់ ចិត្តស្លូតបូត។ [១២]ត្រូវពុះពារតយុទ្ធសម្រាប់ជំនឿឲ្យបានល្អប្រសើរ ហើយឈោងចាប់យកជីវិតអស់កល្បជានិច្ច ដ្បិតព្រះជាម្ចាស់បានត្រាស់ហៅប្អូនមក ឲ្យទទួលជីវិតអស់កល្បជានិច្ចនេះ ដូចប្អូនបានទទួលស្គាល់ ក្នុងពេលប្រកាសជំនឿយ៉ាងល្អប្រពៃ នៅចំពោះមុខមនុស្សជាច្រើនដែលជាសាក្សី។ [១៣]នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ដែលប្រទានឲ្យអ្វីៗទាំងអស់មានជីវិត និង នៅចំពោះព្រះភ័ក្ត្រព្រះគ្រីស្ដយេស៊ូ ដែលបានផ្ដល់សក្ខីភាព ដោយប្រកាសជំនឿយ៉ាងល្អប្រពៃ នៅមុខលោកប៉ុនទីឡាត ខ្ញុំសុំដាស់តឿនប្អូនថា [១៤]ចូរប្រតិបត្តិតាមវិន័យឲ្យបានល្អឥតខ្ចោះ ឥតកំហុស រហូតដល់ពេលព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃយើងសម្ដែងព្រះអង្គ[១៥]គឺព្រះជាម្ចាស់នឹងបង្ហាញព្រះគ្រីស្ដ នៅពេលកំណត់។

*ព្រះជាម្ចាស់ប្រកបដោយសុភមង្គល មានតែព្រះអង្គមួយគត់ដែលជាព្រះអធិបតី ព្រះអង្គជាព្រះមហាក្សត្រធំលើសមហាក្សត្រនានា ជាព្រះអម្ចាស់ធំលើសអម្ចាស់នានា។*

*[១៦]មានតែព្រះអង្គមួយគត់ដែលមានព្រះជន្មអមត ព្រះអង្គគង់នៅក្នុងពន្លឺ ដែលគ្មាននរណាអាចចូលជិតបានឡើយ ហើយក៏គ្មានមនុស្សណាបានឃើញ និងអាចឃើញព្រះអង្គបានដែរ សូមលើកតម្កើងព្រះកិត្តិនាម និង ព្រះចេស្ដារបស់ព្រះអង្គអស់កល្បជានិច្ច! អាម៉ែន!*

[១៧]ចូរដាស់តឿនពួកអ្នកមាន នៅលោកីយ៍នេះ កុំឲ្យវាយឫក និងកុំយកទ្រព្យសម្បត្តិដែលមិនទៀងនោះធ្វើជាទីសង្ឃឹមឡើយ គឺត្រូវសង្ឃឹមលើព្រះជាម្ចាស់ ដែលប្រទានឲ្យយើងមានអ្វីៗទាំងអស់យ៉ាងបរិបូណ៌ សម្រាប់ឲ្យយើងប្រើប្រាស់នោះវិញ។ [១៨]ត្រូវឲ្យគេប្រព្រឹត្តអំពើល្អ ឲ្យគេធ្វើជាអ្នកមានផ្នែកខាងបុណ្យទាន ឲ្យគេមានចិត្តទូលាយ ចេះចែករំលែកដល់អ្នកឯទៀតៗ [១៩]ធ្វើដូច្នេះគេនឹងសន្សំសម្បត្តិដ៏ល្អគង់វង្សសម្រាប់លោកខាងមុខ ដើម្បីឲ្យបានជីវិតដ៏ពិតប្រាកដ។

[២០]ប្អូនធីម៉ូថេអើយ! ចូររក្សាទុកនូវសេចក្ដីដែលព្រះជាម្ចាស់បានផ្ញើនឹងប្អូន!។ ត្រូវចៀសវាងពាក្យសម្ដីឥតន័យ ឥតខ្លឹមសារ និងចៀសវាងការជជែកទាស់ទែងអំពីចំណេះក្លែងក្លាយ។ [២១]មានអ្នកខ្លះ ប្រកាន់យកចំណេះបែបនោះ ហើយត្រូវវង្វេងចេញពីជំនឿ។

សូមព្រះជាម្ចាស់ប្រោសប្រណីបងប្អូនទាំងអស់គ្នា។

ក. សូមអានកិច្ចការ១៦. ១។

ខ. យើងអាចបកប្រែថា:«ត្រូវមានភរិយាតែម្ដងប៉ុណ្ណោះ»ឬ«ត្រូវស្រឡាញ់ភរិយារបស់ខ្លួនដោយចិត្តស្មោះ»ក៏បាន។•គ.ឃ្លាដើម: «កាន់តាមគម្រោងការដ៏លាក់កំបាំងនៃជំនឿ»។•ឃ. យើងអាចបកស្រាយពីរយ៉ាង:ស្ត្រីៗដែលមានមុខងារជាឧបដ្ឋាកឬភរិយារបស់ឧបដ្ឋាក។•ង. សូមអានសេចក្ដីពន្យល់នៅខ.២។

ច.ឃ្លាដើម«ស្មារតីរបស់គេមានដៅសញ្ញាសំគាល់ដោយដែកដែលគេដុត»។នៅជំនាន់នោះគេតែងដៅអ្នកទោសឧក្រិដ្ឋ និងទាសករដោយដែកដែលគេដុតជាត្រាសំគាល់។ ឃ្លានេះមានន័យថាស្មារតីរបស់គេមិនស្គាល់អាក្រក់មិនស្គាល់ល្អ។

ឆ. គឺស្ត្រីមេម៉ាយដែលប្ដីស្លាប់។ • ជ.ឃ្លាដើម: «ត្រូវជួយស្ត្រីមេម៉ាយណាដែលពិតជាមេម៉ាយមែន»។

ឈ. យើងអាចបកប្រែម្យ៉ាងទៀតថា «ត្រូវជូនប្រាក់ខែគាត់មួយទ្វេជាពីរ»។ • ញ. ទុតិយកថា ២៥.៤។ • ដ. លូកា ១០.៧។

# លិខិតទី២ របស់គ្រីស្តទូតប៉ូល ផ្ញើជូនលោកធីម៉ូថេ

## ពាក្យជម្រាបសួរ

[១]ខ្ញុំប៉ូល ជាគ្រីស្តទូតរបស់ព្រះគ្រីស្តយេស៊ូ
១តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បី
ប្រកាសអំពីជីវិតដែលយើងមានក្នុងអង្គព្រះគ្រី
ស្តយេស៊ូ ស្របតាមព្រះបន្ទូលសន្យា[២]មកដល់
ធីម៉ូថេ ជាកូនដ៏ជាទីស្រឡាញ់ សូមព្រះជាម្ចាស់
ជាព្រះបិតា និងព្រះគ្រីស្តយេស៊ូ ជាព្រះអម្ចាស់
នៃយើងប្រោសប្រណី មេត្តាករុណានិងប្រទាន
សេចក្ដីសុខសាន្តដល់ប្អូន។

## ពាក្យអរព្រះគុណ

[៣]ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលខ្ញុំ
គោរពបម្រើបន្តពីបុព្វបុរស* ដោយស្មារតី
បរិសុទ្ធ* ហើយរាល់ពេលខ្ញុំអធិដ្ឋាន*ខ្ញុំតែងតែ
នឹកគិតដល់បងប្អូនឥតឈប់ឈរ ទាំងយប់ទាំង
ថ្ងៃ។ [៤]ខ្ញុំនឹកឃើញទឹកភ្នែករបស់ប្អូន ហើយចង់
ជួបអ្នកជាថ្មីយ៉ាងខ្លាំង ដើម្បីឲ្យខ្ញុំបានពោរពេញ
ដោយអំណរ។ [៥]ខ្ញុំក៏នៅនឹកចាំពីជំនឿឥតលាក់
ពុតរបស់ប្អូន គឺជាជំនឿដែលលោកយាយឡូអ៊ី
សជាជីដូន និងអ្នកស្រីអឺនីសជាម្ដាយរបស់ប្អូន
ធ្លាប់មានមុនប្អូន ខ្ញុំជឿជាក់ថា ប្អូនក៏មានជំនឿ
នេះដែរ។ [៦]ហេតុនេះហើយបានជាខ្ញុំសុំរំឭក

ដាស់តឿនប្អូនថា ចូរធ្វើឲ្យព្រះអំណោយទាន
របស់ព្រះជាម្ចាស់ ដែលប្អូនបានទទួលដោយខ្ញុំ
ដាក់ដៃ*លើនោះ មានសកម្មភាពឡើងវិញ ៧
ដ្បិតព្រះជាម្ចាស់ពុំបានប្រទានឲ្យយើងមាន
វិញ្ញាណដែលនាំឲ្យខ្លាចទេ គឺព្រះអង្គប្រទានឲ្យ
យើងទទួលវិញ្ញាណ ដែលផ្ដល់កម្លាំងសេចក្ដី
ស្រឡាញ់ និងចិត្តធ្ងន់។ ៨ដូច្នេះមិនត្រូវខ្មាស
នឹងផ្ដល់សក្ខីភាព អំពីព្រះអម្ចាស់របស់យើង ឬ
ខ្មាសនឹងខ្ញុំជាប់ឃុំឃាំង ព្រោះតែព្រះអង្គនោះ
ឡើយ។ ផ្ទុយទៅវិញ អ្នកត្រូវតែរងទុក្ខវេទនារួម
ជាមួយខ្ញុំ សម្រាប់ដំណឹងល្អ*ដោយពឹងផ្អែក
លើឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ ៩ព្រះអង្គ
ហ្នឹងហើយដែលបានសង្គ្រោះយើង និងបាន
ត្រាស់ហៅយើងឲ្យជាជនដ៏វិសុទ្ធ*របស់ព្រះអង្គ
[ក]។ ព្រះអង្គត្រាស់ហៅយើងដូច្នេះ មិនមែនមក
ពីអំពើដែលយើងបានប្រព្រឹត្តនោះទេ គឺស្រប
តាមគម្រោងការ និងស្របតាមព្រះហឫទ័យ
ប្រោសប្រណី ដែលទ្រង់បានប្រទានមកយើង
ក្នុងអង្គព្រះគ្រីស្តយេស៊ូ តាំងពីមុនកាលសម័យ
ទាំងអស់ មកម្ល៉េះ។ ១០ឥឡូវនេះ ព្រះអង្គបាន
សម្តែងឲ្យយើងស្គាល់ព្រះហឫទ័យប្រោស
ប្រណីរបស់ព្រះអង្គ ដោយព្រះគ្រីស្តយេស៊ូជា
ព្រះសង្គ្រោះរបស់យើងយាងមកក្នុងលោកនេះ
[ខ]។ ព្រះគ្រីស្តបានបំបាត់អំណាចនៃសេចក្ដី
ស្លាប់ ព្រមទាំងបំភ្លឺយើងឲ្យស្គាល់ជីវិតអមតៈ
ដោយសារដំណឹងល្អ*។

១១ព្រះជាម្ចាស់បានតែងតាំងខ្ញុំ ឲ្យប្រកាស
ដំណឹងល្អនេះ ក្នុងឋានៈជាគ្រីស្តទូត និងជាគ្រូ
អាចារ្យ។ ១២ហេតុនេះហើយបានជាខ្ញុំរងទុក្ខ
លំបាកទាំងនេះ ប៉ុន្តែខ្ញុំមិនខ្មាសឡើយ ដ្បិតខ្ញុំ
ដឹងថា ខ្ញុំបានជឿលើព្រះអង្គណា ហើយខ្ញុំក៏ជឿ
ជាក់ថា ព្រះអង្គនោះមានឫទ្ធានុភាពនឹងរក្សា
សេចក្ដីដែលព្រះអង្គផ្ញើទុកនឹងខ្ញុំ ឲ្យបានគង់វង្ស
រហូតដល់ថ្ងៃព្រះអង្គយាងមក។

១៣ចូរចងចាំព្រះបន្ទូលដ៏ត្រឹមត្រូវរបស់ព្រះ
អម្ចាស់ដែលអ្នកបានទទួលពីខ្ញុំ ទុកធ្វើជាគោល
នៃជំនឿ និងគោលនៃសេចក្ដីស្រឡាញ់ដែល
យើងមាន ដោយរួមក្នុងអង្គព្រះគ្រីស្តយេស៊ូ។
១៤សេចក្ដីដ៏ល្អដែលព្រះអង្គផ្ញើទុកមក ប្អូនត្រូវ
រក្សាឲ្យបានគង់វង្ស ដោយព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលសណ្ឋិតនៅក្នុងយើង។

១៥បងប្អូននៅស្រុកអាស៊ី បោះបង់ខ្ញុំចោល
ទាំងអស់គ្នា មានភីកែឡុស និងហ៊ែរម៉ូគែន ជា
ដើម ដូចប្អូនដឹងស្រាប់ហើយ។ ១៦សូមព្រះ
អម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណាដល់
ក្រុមគ្រួសាររបស់បងអូនេស៊ីភ័រ ដ្បិតគាត់តែង
តែលើកទឹកចិត្តខ្ញុំជាញឹកញាប់ ហើយគាត់ក៏មិន
ដែលខ្មាស ព្រោះតែខ្ញុំជាប់ឃុំឃាំងនោះឡើយ
។ ១៧មិនតែប៉ុណ្ណោះសោត ពេលគាត់មកដល់
ក្រុងរ៉ូម គាត់បានស្វះស្វែងដើររកខ្ញុំទាល់តែជួ
ប។ ១៨សូមព្រះអម្ចាស់ប្រោសប្រទានឲ្យគាត់
បានទទួលព្រះហឫទ័យមេត្តាករុណា ពីព្រះ
អម្ចាស់ នៅថ្ងៃព្រះអង្គយាងមក។ ប្អូនដឹងច្បាស់
ជាងគេស្រាប់ហើយថា កាលខ្ញុំនៅក្រុងអេភេសូ
គាត់បានជួយជ្រោមជ្រែងខ្ញុំច្រើនណាស់។

## ទាហានដ៏ស្មោះត្រង់របស់ព្រះគ្រីស្ទ

[១]ដូច្នេះ ចូរតាំងចិត្តក្លាហានឡើង! កូនអើយ! ២ដោយពឹងផ្អែកលើព្រះហឫទ័យប្រោសប្រណីដែលយើងទទួល ដោយរួមក្នុងអង្គព្រះគ្រីស្តយេស៊ូ។ [២]សេចក្ដីទាំងអស់ដែលប្អូនបានឮពីខ្ញុំនៅមុខសាក្សីជាច្រើននាក់ ចូរប្រគល់ឲ្យបងប្អូនណាដែលស្មោះត្រង់ និងមានសមត្ថភាពអាចបង្រៀនបន្តទៅអ្នកផ្សេងទៀត។

[៣]ចូររួមរងទុក្ខលំបាកក្នុងឋានៈជាទាហានដ៏ល្អរបស់ព្រះគ្រីស្តយេស៊ូ។ [៤]ពេលទាហានចេញទៅច្បាំង គេមិនគិតពីបញ្ហាក្នុងជីវិតសាមញ្ញនេះទេ គឺគេគិតតែធ្វើយ៉ាងណាឲ្យអ្នកដែលជាចៅហ្វាយរបស់ខ្លួនពេញចិត្ត។ [៥]កីឡាករក៏អាចទទួលភ្នួងជ័យបាន លុះត្រាតែគេប្រកួតត្រឹមត្រូវតាមក្បួន។ [៦]កសិករដែលបានធ្វើការយ៉ាងនឿយហត់ ត្រូវតែទទួលភោគផលមុនគេ។ [៧]ចូរពិចារណាឲ្យយល់សេចក្ដី ដែលខ្ញុំនិយាយនេះ ដ្បិតព្រះអម្ចាស់នឹងប្រទានឲ្យអ្នកមានប្រាជ្ញា អាចយល់បានទាំងអស់។

[៨]ចូរនឹកដល់ព្រះយេស៊ូគ្រីស្ត ដែលតើនឡើងពីចំណោមមនុស្សស្លាប់ ហើយព្រះអង្គជាប់ព្រះញាតិវង្សនឹងព្រះបាទដាវីឌ ស្របតាមដំណឹងល្អដែលខ្ញុំប្រកាស។ [៩]ខ្ញុំរងទុក្ខលំបាកព្រោះតែដំណឹងល្អនេះ រហូតដល់ត្រូវគេចាប់ចង ដូចជាជនប្រព្រឹត្តអំពើអាក្រក់។ ប៉ុន្តែគេមិនអាចចាប់ចងព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានឡើយ។ [១០]ហេតុនេះហើយបានជាខ្ញុំសុខចិត្តស៊ូទ្រាំគ្រប់បែបយ៉ាង ដោយយល់ដល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីឲ្យគេទទួលការសង្គ្រោះ ដោយរួមក្នុងអង្គព្រះគ្រីស្តយេស៊ូ ព្រមទាំងទទួលសិរីរុងរឿងអស់កល្បជានិច្ចនោះដែរ។ [១១]ពាក្យនេះគួរឲ្យជឿ គឺថា៖ *ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏នឹងរស់រួមជាមួយព្រះអង្គដែរ។* [១២]*ប្រសិនបើយើងស៊ូទ្រាំ យើងនឹងគ្រងរាជ្យរួមជាមួយព្រះអង្គ។ ប្រសិនបើយើងបដិសេធមិនទទួលស្គាល់ព្រះអង្គ ព្រះអង្គក៏នឹងបដិសេធមិនទទួលស្គាល់យើងដែរ។* [១៣]*ប្រសិនបើយើងមិនស្មោះត្រង់ ព្រះអង្គនៅតែស្មោះត្រង់ដដែល ដ្បិតព្រះអង្គពុំអាចបដិសេធព្រះអង្គផ្ទាល់ បានឡើយ។*

## អ្នកបម្រើដែលមានចិត្តស្មោះត្រង់

[១៤]ប្អូនត្រូវរំឭកដាស់តឿនបងប្អូន ទាំងបញ្ជាក់យ៉ាងម៉ឺងម៉ាត់ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ឲ្យគេចៀសវាងឈ្លោះប្រកែកគ្នា អំពីពាក្យពេចន៍ ព្រោះគ្មានបានផលប្រយោជន៍អ្វីឡើយ គឺនាំតែកើតអន្តរាយដល់អ្នកស្ដាប់តែប៉ុណ្ណោះ។ [១៥]ចូរខំប្រឹងធ្វើយ៉ាងណា ឲ្យបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងចូលជិតព្រះអង្គ ក្នុងឋានៈជាអ្នកធ្វើការដែលគ្មានអ្វីនាំឲ្យអៀនខ្មាស ព្រោះខ្លួនបានចែករំលែកព្រះបន្ទូល នៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ។ [១៦]ត្រូវចៀសវាងពាក្យព្រោកប្រាជ្ញ ដែលទាស់នឹងព្រះជាម្ចាស់ ដ្បិតពួកអ្នកចូលចិត្តពាក្យព្រោកប្រាជ្ញបែបនេះ រមែងតែងតែឃ្លាតចេញពីព្រះជាម្ចាស់ កាន់តែឆ្ងាយទៅៗ។ [១៧]ពាក្យសម្ដីរបស់ពួកគេ ប្រៀបបីដូចជាដំបៅស៊ីរូងកាន់តែជ្រៅទៅៗ។ ក្នុងចំណោមអ្នកទាំងនោះមានហ៊ីមេណា និង ភីឡេតូ។ [១៨]អ្នកទាំងពីរបានឃ្លាតឆ្ងាយពីសេចក្ដីពិត ដោយពោលថា

មនុស្សស្លាប់ទទួលជីវិតថ្មីរួចហើយ! គេក៏បង្វែរ
បងប្អូនខ្លះឲ្យលះបង់ជំនឿ។ ១៩ក៏ប៉ុន្តែទោះជា
យ៉ាងណាក៏ដោយ គ្រឹះដ៏មាំដែលព្រះជាម្ចាស់
បានចាក់នោះនៅតែស្ថិតស្ថេររឹងប៉ឹងដដែល
ហើយនៅលើគ្រឹះនោះមានចារឹកពាក្យជាសញ្ញា
សម្គាល់ថា៖ *«ព្រះអម្ចាស់ស្គាល់កូនចៅរបស់
ព្រះអង្គ»*[គ] ហើយ *«អ្នកណាប្រកាសថាខ្លួន
គោរពព្រះនាមព្រះអម្ចាស់ អ្នកនោះត្រូវតែងាក
ចេញឲ្យផុតពីអំពើទុច្ចរិត»*[ឃ]។

២០នៅក្នុងផ្ទះមួយដ៏ធំមិនមែនមានតែគ្រឿង
ប្រដាប់ធ្វើពីមាស ឬពីប្រាក់ប៉ុណ្ណោះទេ គឺមាន
គ្រឿងប្រដាប់ធ្វើពីឈើ និងធ្វើពីដីដែរ គឺគ្រឿង
ប្រដាប់មួយផ្នែក សម្រាប់ប្រើប្រាស់ក្នុងឱកាស
ពិសេស ហើយមួយផ្នែកទៀតសម្រាប់ប្រើ
ប្រាស់ជាធម្មតា។ ២១ដូច្នេះប្រសិនបើអ្នកណា
ម្នាក់ជម្រះខ្លួនបានបរិសុទ្ធ ផុតពីអំពើអាក្រក់
ទាំងនេះហើយ ព្រះជាម្ចាស់នឹងប្រើអ្នកនោះ
ទុកដូចជាឧបករណ៍វិសេសដ៏វិសុទ្ធ* មាន
ប្រយោជន៍ដល់ម្ចាស់ និងអាចប្រើប្រាស់
សម្រាប់ធ្វើអំពើល្អគ្រប់យ៉ាង។

២២ចូរគេចពីចំណង់តណ្ហានៃយុវវ័យ ហើយ
ខំប្រឹងស្វែងរកសេចក្ដីសុចរិត ជំនឿ សេចក្ដី
ស្រឡាញ់ សេចក្ដីសុខសាន្តជាមួយអស់អ្នក
ដែលគោរពព្រះអម្ចាស់ ដោយចិត្តបរិសុទ្ធ*
នោះវិញ។ ២៣ចូរចៀសវាងការជជែកវែកញែក
ដ៏ល្ងីល្ងើផ្ដេសផ្ដាស ត្រូវដឹងថាការជជែកវែក
ញែកបែបនេះ បង្កឲ្យតែមានជម្លោះប៉ុណ្ណោះ
២៤អ្នកបម្រើរបស់ព្រះអម្ចាស់មិនត្រូវឲ្យមានការ
ឈ្លោះប្រកែកគ្នាឡើយ ផ្ទុយទៅវិញ ត្រូវ
រួសរាយចំពោះមនុស្សទូទៅ ត្រូវចេះបង្រៀន
និងសុខចិត្តឲ្យគេរិះគន់ ២៥ត្រូវមានចិត្តស្លូតបូត
ប្រៀនប្រដៅអ្នកប្រឆាំង។ ប្រហែលជាព្រះជា
ម្ចាស់នឹងប្រោសប្រទាន ឲ្យគេកែប្រែចិត្តគំនិត
ដើម្បីឲ្យគេបានស្គាល់សេចក្ដីពិត យ៉ាងច្បាស់
២៦ព្រមទាំងភ្ញាក់ស្មារតី អាចដោះខ្លួនរួចពីអន្ទាក់
របស់មារ*ដែលបានចាប់ចងគេ បង្ខំគេឲ្យធ្វើ
តាមបំណងរបស់វា។

## ព្រឹត្តការណ៍នៅគ្រាចុងក្រោយ

១ប្អូនត្រូវដឹងថា នៅពេលចុងក្រោយបង្អស់
៣នឹងមានគ្រាលំបាក ២មនុស្សម្នានឹងមានចិត្ត
អាត្មានិយម មានចិត្តលោភលន់ ស្រឡាញ់
ប្រាក់ ក្រអឺតក្រទម អួតខ្លួន ប្រមាថព្រះជាម្ចាស់
មិនស្ដាប់បង្គាប់ឪពុកម្ដាយ រមិលគុណ បំផ្លាញ
អ្វីៗដែលជាសក្ការៈ ៣គេជាមនុស្សអត់ចិត្ត គ្មាន
អធ្យាស្រ័យ និយាយមួលបង្កាច់ មិនចេះទប់ចិត្ត
ឃោរឃៅ ស្អប់អំពើល្អ ៤ជាមនុស្សមានចិត្តក្បត់
ឆាប់ច្រឡោត អួតបំប៉ោង ចូលចិត្តសប្បាយជា
ជាងស្រឡាញ់ព្រះជាម្ចាស់។ ៥គេសម្ដែងអាកា
រៈខាងក្រៅ ជាអ្នកគោរពប្រណិប័តន៍ព្រះជា
ម្ចាស់ ប៉ុន្តែគេបដិសេធមិនទទួលស្គាល់
ឫទ្ធានុភាព ដែលមកពីការគោរពប្រណិប័តន៍
ព្រះអង្គ នោះឡើយ។ ចូរចៀសចេញឲ្យឆ្ងាយ
ពីមនុស្សប្រភេទនេះដែរ។ ៦ក្នុងចំណោមពួកគេ
អ្នកខ្លះបានឆ្លៀតចូលផ្ទះនានា ហើយទាក់យក
ស្ត្រីឆោតៗ ដែលពោរពេញទៅដោយអំពើបាប
ជាស្ត្រីបណ្ដោយខ្លួន ទៅតាមតណ្ហាគ្រប់យ៉ាងផ
ង។ ៧ស្ត្រីៗទាំងនោះរៀនមិនចេះចប់ ហើយ
នៅតែ មិនអាចស្គាល់សេចក្ដីពិតដដែល។

៨ កាលពីដើមយ៉ាណែ និងយ៉ម្ប្រែ[ង] ប្រឆាំងនឹង
លោកម៉ូសេយ៉ាងណា អ្នកទាំងនេះក៏ប្រឆាំងនឹង
សេចក្ដីពិតយ៉ាងនោះដែរ។ ពួកគេជាមនុស្ស
មានគំនិតខូច ហើយជំនឿរបស់គេ ឥតបានការ
អ្វីទាល់តែសោះ។ ៩ ប៉ុន្តែ គេពុំអាចទៅមុខទៀត
បានឆ្ងាយឡើយ ដ្បិតមនុស្សម្នានឹងឃើញគំនិត
លេលារបស់គេ ដូចមនុស្សនៅសម័យដើមបាន
ឃើញគំនិតលេលារបស់យ៉ាណែ និងយ៉ម្ប្រែ
ដែរ។

## ពាក្យរំឭកជាស់តឿនផ្សេងៗ

១០ ចំពោះប្អូនវិញ ប្អូនបាននៅជាមួយខ្ញុំក្នុង
ពេលខ្ញុំបង្រៀន ប្អូនបានឃើញកិរិយារបស់ខ្ញុំ
ឃើញគម្រោងការ ជំនឿ ការអត់ធ្មត់ ការ
ស្រឡាញ់ និងការស៊ូទ្រាំរបស់ខ្ញុំ ១១ប្អូនបាន
ឃើញគេធ្វើទុក្ខបុកម្នេញខ្ញុំ និងបានឃើញទុក្ខ
លំបាក ដែលកើតមានដល់ខ្ញុំ នៅក្រុងអន់ទីយ៉ូ
ក ក្រុងអ៊ីកូញ៉ូម និងក្រុងលីស្ត្រា។ ខ្ញុំបានរងទុក្ខ
វេទនាដោយគេធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ក៏
ប៉ុន្តែ ព្រះអម្ចាស់បានរំដោះខ្ញុំ ឲ្យរួចផុតទាំងអ
ស់។ ១២អស់អ្នកដែលចង់រស់នៅដោយគោរព
ប្រណិប័តន៍ព្រះជាម្ចាស់ ក្នុងព្រះគ្រីស្ដយេស៊ូ
មុខជាត្រូវគេបៀតបៀន ដូច្នេះឯង។ ១៣រីឯ
មនុស្សអាក្រក់ និងអ្នកបោកប្រាសវិញ គេចេះ
តែប្រព្រឹត្តអំពើអាក្រក់ កាន់តែច្រើនឡើងៗ
ទាំងនាំអ្នកផ្សេងឲ្យវង្វេង ហើយខ្លួនគេផ្ទាល់ក៏
វង្វេងដែរ។

១៤ ចំពោះប្អូន ប្អូន ត្រូវកាន់តាមសេចក្ដី
ដែលប្អូនបានរៀន និងយកធ្វើជាគោលជំនឿ
ឲ្យបានខ្ជាប់ខ្ជួន! ប្អូនដឹងច្បាស់ហើយថា ប្អូន
បានរៀនសេចក្ដីទាំងនេះពីនរណាមក!។ ១៥
ប្អូនស្គាល់ព្រះគម្ពីរតាំងតែពីនៅកុមារម្ល៉េះ
ហើយព្រះគម្ពីរអាចផ្ដល់ឲ្យប្អូនមានប្រាជ្ញា ដើម្បី
នឹងទទួលការសង្គ្រោះ ដោយមានជំនឿលើព្រះ
គ្រីស្ដយេស៊ូ។ ១៦គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះ
ជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង និង
មានប្រយោជន៍សម្រាប់បង្រៀន រកខុសត្រូវ កែ
តម្រង់ និងអប់រំឲ្យរស់នៅតាមសេចក្ដីសុចរិត
១៧ក្នុងគោលបំណង ឲ្យអ្នកបម្រើរបស់ព្រះជា
ម្ចាស់មានសមត្ថភាព និងប្រុងប្រៀបខ្លួនជា
ស្រេចដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក។

១ ខ្ញុំសុំបញ្ជាក់យ៉ាងម៉ឺងម៉ាត់ នៅចំពោះព្រះភ័
៤ក្ត្រព្រះជាម្ចាស់ និងនៅចំពោះព្រះភ័ក្ត្រព្រះគ្រី
ស្ដយេស៊ូ ដែលនឹងវិនិច្ឆ័យទោសទាំងមនុស្ស
រស់ ទាំងមនុស្សស្លាប់ ហើយខ្ញុំសូមបញ្ជាក់
ដោយទ្រង់សម្ដែងព្រះអង្គ និងគ្រងរាជ្យ[ច]នោះ
ថា ២ចូរប្រកាសព្រះបន្ទូល ព្រមទាំងនិយាយ
ហើយនិយាយទៀត ទោះត្រូវពេលក្ដីខុសពេល
ក្ដី ត្រូវរកខុសត្រូវ ស្ដីបន្ទោស ដាស់តឿន និង
បង្រៀនគេដោយចិត្តអត់ធ្មត់គ្រប់ជំពូក ៣ដ្បិត
នឹងមានគ្រាមួយដែលមនុស្សលោកមិនព្រម
ស្ដាប់ សេចក្ដីបង្រៀនដ៏ត្រឹមត្រូវទេ ផ្ទុយទៅវិញ
គេរកគ្រូមកបង្រៀនតាមទំនើងចិត្ត[ឆ]របស់គេ
គ្រាន់តែឲ្យពីរោះត្រចៀកប៉ុណ្ណោះ។ ៤គេងាក
ចេញពីសេចក្ដីពិត ហើយបែរទៅស្ដាប់រឿង
ព្រេងនិទានវិញ។ ៥ចំពោះប្អូនចូរមានស្មារតី
រឹងប៉ឹងគ្រប់វិស័យទាំងអស់ ត្រូវស៊ូទ្រាំនឹងទុក្ខ
លំបាក ត្រូវបំពេញកិច្ចការជាអ្នកប្រកាស

ដំណឹងល្អ ព្រមទាំងបំពេញមុខងាររបស់ខ្លួនឲ្យ
បានល្អប្រសើរផង។

៦រីឯខ្ញុំវិញ ខ្ញុំបានបូជាជីវិតរួចស្រេចហើយ
ហើយក៏ដល់ពេលកំណត់ ដែលខ្ញុំត្រូវចាកចេញ
ពីលោកនេះដែរ។ ៧ខ្ញុំបានពុះពារតយុទ្ធល្អ
ប្រសើរ ខ្ញុំបានរត់ដល់ទីដៅ ហើយខ្ញុំនៅតែកាន់
ជំនឿជាប់ដដែល។ ៨ឥឡូវនេះព្រះអម្ចាស់ជា
ចៅក្រមដ៏សុចរិតបានបម្រុងភួងជ័យនៃសេចក្ដី
សុចរិតសម្រាប់ខ្ញុំ ហើយព្រះអង្គនឹងប្រទានឲ្យខ្ញុំ
នៅថ្ងៃដែលព្រះអង្គយាងមក ទ្រង់មិនត្រឹមតែ
ប្រទានឲ្យខ្ញុំម្នាក់ប៉ុណ្ណោះទេ គឺប្រទានឲ្យអស់
អ្នកដែលទន្ទឹងរង់ចាំព្រះអង្គ យាងមកនោះ
ដោយចិត្តស្រឡាញ់។

## ពាក្យជាស់តឿនផ្សេងៗ

៩ចូរលៃលកទៅរកខ្ញុំជាប្រញាប់។ ១០បងដេ
ម៉ាបោះបង់ចោលខ្ញុំ ព្រោះគាត់ស្រឡាញ់
លោកីយ៍នេះ ហើយចេញដំណើរទៅក្រុងថេ
ស្សាឡូនិក។ បងក្រេស្កេនបានទៅស្រុកកាឡា
ទី ហើយបងទីតូទៅស្រុកដាល់ម៉ាទី។ ១១មាន
តែបងលូកាម្នាក់ប៉ុណ្ណោះ ដែលនៅជាមួយខ្ញុំ។
ចូរនាំបងម៉ាកូទៅជាមួយផង ដ្បិតគាត់អាចជួយ
បំពេញមុខងាររបស់ខ្ញុំបាន។១២ខ្ញុំចាត់បងទីឃីគូ
ឲ្យទៅក្រុងអេភេសូ។ ១៣ពេលប្អូនចេញទៅ ចូរ
យកអាវធំដែលខ្ញុំទុកនៅផ្ទះបងការពូ នៅក្រុង
ត្រូអា ព្រមទាំងយកសៀវភៅមកជាមួយផង ជា
ពិសេសកុំភ្លេចយកក្រាំងស្បែកទៅផង។

១៤បងអេឡិចសង់ ជាជាងដែក បានធ្វើបាប
ខ្ញុំយ៉ាងច្រើន។ ព្រះអម្ចាស់នឹងតបស្នងទៅគាត់
វិញ តាមអំពើដែលគាត់បានប្រព្រឹត្តនោះជាមិន
ខាន។ ១៥ប្អូនក៏ត្រូវប្រយ័ត្ននឹងគាត់ដែរ ដ្បិត
គាត់ប្រឆាំងយ៉ាងខ្លាំងនឹងសេចក្ដី ដែលយើង
ប្រកាស។

១៦ពេលដែលខ្ញុំត្រូវឆ្លើយដោះសាខ្លួន នៅ
លើកទីមួយ គ្មានបងប្អូនណាម្នាក់មកជួយគាំទ្រ
ខ្ញុំទេ គឺគេបោះបង់ចោលខ្ញុំទាំងអស់គ្នា សូម
ព្រះជាម្ចាស់កុំប្រកាន់ទោសគេឡើយ!។១៧មាន
តែព្រះអម្ចាស់ប៉ុណ្ណោះដែលបានគាំទ្រ និង
ប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាស
ព្រះបន្ទូលយ៉ាងក្បោះក្បាយ ឲ្យសាសន៍ដទៃ
ទាំងអស់គ្នាស្ដាប់។ ព្រះអង្គក៏បានដោះលែងខ្ញុំ
ឲ្យរួចពីមាត់សឹង្ហដែរ។ ១៨ព្រះអម្ចាស់នឹងរំដោះ
ខ្ញុំឲ្យរួចពីសេចក្ដីអាក្រក់គ្រប់យ៉ាង ហើយព្រះ
អង្គនឹងសង្គ្រោះខ្ញុំ ដើម្បីឲ្យខ្ញុំចូលទៅក្នុងព្រះ
រាជ្យ*របស់ព្រះអង្គ នៅស្ថានបរមសុខ។ សូម
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ អស់កល្ប
ជាអង្វែងតរៀងទៅ! អាម៉ែន!

១៩សូមជម្រាបសួរនាងព្រីស្កានិងបងអគីឡា
ព្រមទាំងក្រុមគ្រួសារបងអូនេស៊ីភ័រផង។

២០បងអេរ៉ាស្ទូ ស្នាក់នៅក្រុងកូរិនថូ ហើយខ្ញុំ
បានទុកបងត្រូភីមដែលឈឺឲ្យនៅក្រុងមីលេត។

២១ចូរលៃលកទៅជួបខ្ញុំ ឲ្យបានមុនរដូវរងារ
កុំបីខាន។ បងអឺប៊ូលូស បងពូដេស្ស បងលីណូ
នាងក្លូឌីយ៉ា និងបងប្អូនឯទៀតៗទាំងអស់ សូម
ជម្រាបសួរមកប្អូន។

២២សូមព្រះអម្ចាស់គង់ជាមួយវិញ្ញាណរបស់
ប្អូន!

សូមព្រះអង្គប្រោសប្រណី ដល់បងប្អូនទាំងអស់គ្នា! អាម៉ែន។

ក. យើងអាចបកប្រែថា «ការត្រាស់ហៅដ៏វិសុទ្ធ»ក៏បាន។• ខ.ឃ្លាដើម«ដោយសារព្រះគ្រីស្តយេស៊ូជាព្រះសង្គ្រោះរបស់យើងទ្រង់លេចមក»។

គ. ជំរឿនប្រជាជន(ជនគណនា) ១៦.៥។

ឃ. ទំនុកតម្កើង៩៧.១០ អេសាយ២៦.១៣។ • ង.តាមប្រពៃណីរបស់សាសន៍យូដាយ៉ាណែសនិងយ៉ាមប្រែសជាឈ្មោះគ្រូធ្មប់ជាតិអេស៊ីប ដែលបានប្រឆាំងនឹងលោកម៉ូសេ។ សូមអាន សេរីភាព(និក្ខមនំ) ៧.១១,២២ប៉ា។

ច. ឃ្លាដើម: «ក្នុងនាមនៃការយាងមកយ៉ាងឱឡារឹក និង ក្នុងនាមព្រះរាជ្យរបស់ព្រះអង្គ»។• ឆ.ពាក្យដើម «តណ្ហា»។

# លិខិតរបស់គ្រីស្តទូតប៉ូល

# ផ្ញើជូនលោកភីលេម៉ូន

១ ខ្ញុំប៉ូលនៅជាប់ឃុំឃាំង ព្រោះតែព្រះគ្រីស្ត
យេស៊ូ ព្រមទាំងធីម៉ូថេជាបងប្អូនសូមជម្រាប
មកបងភីលេម៉ូនជាទីស្រឡាញ់ ដែលរួមការងារ
ជាមួយយើង ២ សូមជម្រាបមកប្អូនស្រីអ័ព្យា
សូមជម្រាបមកលោកអឃីពូ ដែលតយុទ្ធរួម
ជាមួយយើង និងសូមជម្រាបមកព្រះសហគមន៍
ដែលប្រជុំគ្នាក្នុងផ្ទះរបស់ប្អូន សូមជ្រាប។

៣ សូមព្រះជាម្ចាស់ ជាព្រះបិតារបស់យើង
និងព្រះយេស៊ូគ្រីស្តជាអម្ចាស់ ប្រោសប្រណី
ប្រទានសេចក្តីសុខសាន្តដល់បងប្អូន។

៤ រាល់ពេលអធិដ្ឋាន ខ្ញុំតែងតែនឹកដល់ប្អូន
ហើយអរព្រះគុណព្រះជាម្ចាស់របស់ខ្ញុំ ជានិច្ច ៥
ដ្បិតខ្ញុំបានឮគេនិយាយ អំពីសេចក្តីស្រឡាញ់
និងជំនឿរបស់ប្អូន ចំពោះព្រះអម្ចាស់យេស៊ូ
និងចំពោះជនដ៏វិសុទ្ធទាំងអស់។ ៦ សូមព្រះអង្គ
ប្រទានឲ្យការរួមជំនឿ ទៅជាកម្លាំងជំរុញចិត្ត
ប្អូន ឲ្យស្គាល់ច្បាស់នូវអ្វីដ៏ល្អគ្រប់យ៉ាង ដែល
យើងអាចធ្វើបានថ្វាយព្រះគ្រីស្ត*។ ៧ ខ្ញុំមាន
អំណរនិងមានកម្លាំងចិត្តយ៉ាងខ្លាំង ដោយ
ឃើញថា ប្អូនមានចិត្តស្រឡាញ់ អាណិត ធ្វើឲ្យ
ជនដ៏វិសុទ្ធបានស្ងប់ចិត្ត។

៨ ទោះបី ខ្ញុំមានសិទ្ធិពេញទីនឹងបង្គាប់ប្អូន

ក្នុងនាមព្រះគ្រីស្ដ ឲ្យធ្វើអ្វីដែលប្អូនត្រូវធ្វើក្ដី ៩ក៏ខ្ញុំចូលចិត្តយកសេចក្ដីស្រឡាញ់អាណិត មកអង្វរប្អូនវិញដែរ។ ខ្ញុំ ប៉ូល ដែលចាស់ទៅហើយ ដែលឥឡូវនេះជាប់ឃុំឃាំង ព្រោះតែព្រះគ្រីស្ដយេស៊ូថែមទៀត ១០ខ្ញុំសូមអង្វរប្អូន ឲ្យកូនរបស់ខ្ញុំ គឺអូនេស៊ីម ដែលខ្ញុំបានបង្កើតនៅពេលជាប់ឃុំឃាំង។ ១១ពីដើមគាត់គ្មានប្រយោជន៍អ្វីសម្រាប់ប្អូនមែន ប៉ុន្តែឥឡូវនេះ គាត់ប្រាកដជានឹងមានប្រយោជន៍សម្រាប់ប្អូនវិញ ក៏ដូចជាមានប្រយោជន៍សម្រាប់ខ្ញុំដែរ។

១២គាត់ប្រៀបដូចជា ថ្លើមប្រមាត់របស់ខ្ញុំ ខ្ញុំសូមចាត់គាត់ឲ្យវិលមករកប្អូនវិញ។ ១៣ខ្ញុំមានបំណងចង់ទុកគាត់ឲ្យនៅជាមួយខ្ញុំ ដើម្បីបម្រើខ្ញុំ ជំនួសប្អូន ក្នុងពេលខ្ញុំជាប់ឃុំឃាំង ព្រោះតែដំណឹងល្អ*នេះ ១៤ក៏ប៉ុន្តែ ខ្ញុំមិនចង់ធ្វើអ្វីដោយគ្មានការយល់ព្រមពីប្អូនឡើយ ដើម្បីកុំឲ្យលោកប្អូនធ្វើអំពើល្អទាំងទើសទាំងទ័ល គឺធ្វើដោយស្ម័គ្រចិត្តវិញ។ ១៥អូនេស៊ីមឃ្លាតឆ្ងាយពីប្អូនមួយរយៈមែន ដើម្បីឲ្យប្អូនបានទទួលគាត់វិញអស់កល្បជានិច្ច ១៦មិនមែនក្នុងឋានៈជាទាសករទៀតទេ គឺក្នុងឋានៈជាបងប្អូនដ៏ជាទីស្រឡាញ់វិញ គឺប្រសើរជាងទាសករទៅទៀត។ គាត់ពិតជា បងប្អូនដ៏ជាទីស្រឡាញ់យ៉ាងខ្លាំងរបស់ខ្ញុំ ហើយចំពោះប្អូន គាត់ក៏រឹតតែជាទីស្រឡាញ់ថែមទៀត ទាំងខាងលោកីយ៍ ទាំងខាងព្រះអម្ចាស់។

១៧ហេតុនេះហើយ ប្រសិនបើ ប្អូនរាប់ខ្ញុំទុកជាបងប្អូនរួមជំនឿមែន សូមទទួលគាត់ឲ្យបានដូចទទួលខ្ញុំផ្ទាល់ដែរ។ ១៨ប្រសិនបើគាត់ធ្វើអ្វីខុស ចំពោះប្អូន ឬប្រសិនបើគាត់ជំពាក់អ្វីប្អូន សូមគិតទៅលើខ្ញុំចុះ។ ១៩ខ្ញុំប៉ូល ខ្ញុំសរសេរពាក្យនេះដោយដៃខ្ញុំផ្ទាល់ថា ខ្ញុំនឹងសងប្អូនវិញ (ខ្ញុំមិនបាច់រំឭកថា ប្អូនក៏នៅជំពាក់ខ្ញុំផងដែរ នោះទេ គឺនៅជំពាក់រូបប្អូនផ្ទាល់តែម្ដង)។ ២០ប្អូន! សូមប្អូនមេត្តាជួយខ្ញុំដោយយល់ដល់ព្រះអម្ចាស់ ហើយសូមធ្វើឲ្យចិត្តខ្ញុំបានស្ងប់ក្នុងអង្គព្រះគ្រីស្ដផង។

២១ខ្ញុំសរសេរមកប្អូន ដោយជឿជាក់ថា ប្អូនមុខជាស្ដាប់តាមសំណូមពររបស់ខ្ញុំ។ ខ្ញុំក៏ដឹងថាប្អូននឹងធ្វើ លើសពីពាក្យដែលខ្ញុំសុំទៅទៀត។ ២២ព្រមជាមួយគ្នានេះ សូមប្អូនរៀបចំកន្លែងមួយសម្រាប់ខ្ញុំស្នាក់ផង ដ្បិតខ្ញុំសង្ឃឹមថានឹងបានមកជួបបងប្អូនមិនខាន ព្រោះបងប្អូនបានទូលអង្វរព្រះជាម្ចាស់ឲ្យខ្ញុំ។

២៣អេប៉ាប្រា ដែលជាប់ឃុំឃាំងជាមួយខ្ញុំ ព្រោះតែព្រះគ្រីស្ដយេស៊ូ សូមជម្រាបសួរមកប្អូន ២៤ហើយបងម៉ាកូ បងអរីស្ដាក បងដេម៉ា និងបងលូកា ជាសហការីរបស់ខ្ញុំ ក៏សូមជម្រាបសួរមកប្អូនដែរ។

២៥សូមព្រះយេស៊ូគ្រីស្ដ ជាព្រះអម្ចាស់នៃយើងប្រោសប្រណីដល់វិញ្ញាណបងប្អូន។